កសិកម្ម

クメール語版 / ឯកសារជាភាសាខ្មែរ

# សៀវភៅណែនាំវិធានការ សុខភាពនិងសុវត្ថិភាព សម្រាប់សិក្ខាកាមកម្មសិក្សា ការីបច្ចេកទេស

ការងារទាក់ទងនឹងវិស័យកសិកម្ម



OTIT 外国人技能実習機構
អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស

# តារាងមាតិកា


1 ទិដ្ឋភាពទូទៅនៃកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស

1 សេចក្តីផ្តើម ........ 1

2 ទិដ្ឋភាពទូទៅនៃកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស ........ 2

3 ការងារទាក់ទងនឹងវិស័យកសិកម្ម និងរក្លាប្រមាញ់ ........ 3

4 បណ្ណលំនៅឋាន ........ 4

2 មូលដ្ឋានសុខភាពនិងសុវត្ថិភាព ........ 6

3 ការអនុវត្តសកម្មភាពសុខភាពនិងសុវត្ថិភាព ........ 15

4 ការធានាសុវត្ថិភាពសម្រាប់គ្រឿងយន្តកសិកម្ម ........ 19

5 ការធានាសុវត្ថិភាពសម្រាប់ឧបករណ៍កសិកម្ម ជណ្តើរជើងបួន និងជណ្តើរជើងពីរ ........ 27

6 ការគ្រប់គ្រងសុខភាពនិងសុវត្ថិភាពនៅក្នុងក្រោលគោ-ក្របី ........ 29

7 ការគ្រប់គ្រងសុវត្ថិភាពថ្នាំសម្លាប់សត្វល្អិត ........ 30

8 វិធានការការពារការសន្លប់ដោយត្រូវកម្តៅខ្លាំង ........ 31

9 វិធានការការពារការឈឺចង្កេះ ........ 34

10 វិធានការការពារការសត្វល្អិតខាំ-ទិច ........ 35

11 វិធានការការពារកង្វះអុកស៊ីសែន ........ 37

12 សារៈសំខាន់នៃទំនាក់ទំនងជាមួយសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស ........ 39

13 ការអនុវត្តការពិនិត្យសុខភាព ........ 40

14 ឧទាហរណ៍ស្តីពីការរងរបួសឧស្សាហកម្ម ........ 42

# 1 ទិដ្ឋភាពទូទៅនៃកម្មវិធីបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស

## 1 សេចក្ដីផ្ដើម

បម្រែបម្រួលចំនួនផែនការបណ្ដុះបណ្ដាលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសដែលបានអនុម័ត




(ប្រភព៖ ស្ថិតិរដ្ឋបាល អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស)

ចំនួននៃផែនការដែលបានអនុម័តនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស បានថយចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំសារពើពន្ធ 2020 និង 2021 បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ដែលរងផលប៉ះពាល់ដោយការរឹតបន្តឹងការធ្វើដំណើរទៅប្រទេសជប៉ុន ដោយសារតែវិធានការនានាដើម្បីការពារការឆ្លងជំងឺ COVID-19 ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួននេះបាននឹងកំពុងកើនឡើងចាប់តាំងពីឆ្នាំសារពើពន្ធឆ្នាំ 2022 នៅពេលដែលការរឹតបន្តឹងការធ្វើដំណើរទៅប្រទេសជប៉ុនត្រូវបានបន្ធូរបន្ថយបន្តិចម្ដងៗមក។ ពេលពិនិត្យមើលចំនួនផែនការដែលបានអនុម័តសម្រាប់ការងារទាក់ទងនឹងវិស័យកសិកម្មលើសពីចំនួនសរុបក្នុងឆ្នាំសារពើពន្ធ 2019 មុនពេលផលប៉ះពាល់នៃការឆ្លងជំងឺ COVID-19 គឺមានចំនួន 32,419 ករណី ប៉ុន្តែនៅក្នុងឆ្នាំ 2023 មានចំនួនត្រឹមតែ 25,077 ករណីប៉ុណ្ណោះ ដែលមានន័យថា ស្ថានភាពមិនទាន់បានធូរស្បើយដល់កម្រិតកាលពីអតីតកាលនៅឡើយទេ។ យ៉ាងណាក៏ដោយ ចំនួនការងារទាក់ទងនឹងវិស័យកសិកម្មជាភាគរយនៃចំនួនផែនការដែលបានអនុម័ត នៅតែមានភាគរយថេរប្រហែល 7.2% នៅក្នុងឆ្នាំសារពើពន្ធ 2023។

ជាងនេះទៅទៀត ស្ទើរតែទាំងអស់នៃស្ថាប័នអនុវត្តដែលធ្វើការបណ្ដុះបណ្ដាលលើការងារទាក់ទងនឹងវិស័យកសិកម្ម គឺជាស្ថាប័នអនុវត្តន៍តាមប្រភេទស្ថាប័នគ្រប់គ្រង ហើយការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេសជាញឹកញាប់ត្រូវបានរៀបចំដោយស្ថាប័នអនុវត្តដែលជាកម្មសិទ្ធិករផ្ដាច់មុខ។ ប៉ុន្តែ កម្មសិទ្ធិករផ្ដាច់មុខទាំងនេះប្រហែលជាមិនអាចអនុវត្តវិធានការសុខភាពនិងសុវត្ថិភាពបានពេញលេញសម្រាប់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសឡើយ ដោយសារពួកគេខ្វះបុគ្គលដែលមានចំណេះដឹងអំពីសុខភាពនិងសុវត្ថិភាព។

សៀវភៅណែនាំនេះចងក្រងព័ត៌មានមួយចំនួនធំរួមគ្នា ដែលបង្កើតជាមូលដ្ឋាននៃវិធានការសុវត្ថិភាពនិងសុខភាពជាក់លាក់ចំពោះការងារដែលទាក់ទងនឹងវិស័យកសិកម្ម។ លើសពីនេះទៀត សៀវភៅណែនាំនេះត្រូវបានសម្រេចឱ្យបោះពុម្ពផ្សាយ រួមជាមួយនឹងសំណៅឯកសារដែលបានបកប្រែជា 9 ភាសា ដើម្បីឱ្យស្ថាប័នអនុវត្តទាំងអស់អាចប្រើប្រាស់ព័ត៌មាននេះដើម្បីផ្ដល់គោលការណ៍ណែនាំដល់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសរបស់ពួកគេ។

យើងសង្ឃឹមថាការប្រើប្រាស់សៀវភៅណែនាំនេះនឹងជួយកែលម្អវិធានការសុវត្ថិភាពនិងសុខភាពសម្រាប់អ្នកគ្រប់រូបដែលពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស។

# 2 ទិដ្ឋភាពទូទៅនៃកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស

ឆ្នាំទី 1

ការបង្រៀន

(i) ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស — ការបណ្តុះបណ្តាល

○ចូលប្រទេសជប៉ុន
ស្ថានភាពស្នាក់នៅក្នុងប្រទេសជប៉ុន៖ "ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (i) ចំណុច (a), (b)"

ការបង្រៀន (សិក្សាក្នុងថ្នាក់)
ជាគោលការណ៍ មានរយៈពេល 2 ខែ នៅស្ថាប័នអនុវត្ត (សម្រាប់តែប្រភេទបណ្តុះបណ្តាលបុគ្គល-សហគ្រាសប៉ុណ្ណោះ) ឬស្ថាប័នគ្រប់គ្រង (គ្មានទំនាក់ទំនងការងារ)

ការបណ្តុះបណ្តាល
នៅស្ថាប័នអនុវត្ត (មានទំនាក់ទំនងការងារ)
*ការបណ្តុះបណ្តាលប្រភេទស្ថាប័នគ្រប់គ្រង៖ ស្ថាប័នគ្រប់គ្រងណែនាំ និងត្រួតពិនិត្យនៅនឹងកន្លែងដោយស្ថាប័នគ្រប់គ្រង

ធ្វើតេស្តជំនាញ (កម្រិតមូលដ្ឋាន) ឬធ្វើតេស្តវាយតម្លៃការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (កម្រិតដំបូង)

ឆ្នាំទី 2

(ii) ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស — ការបណ្តុះបណ្តាល

○ ផ្លាស់ប្តូរ ឬទទួលបានស្ថានភាពស្នាក់នៅក្នុងប្រទេសជប៉ុន
ស្ថានភាពស្នាក់នៅក្នុងប្រទេសជប៉ុន៖ "ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (ii) ចំណុច (a), (b)"
① ការងារគោលដៅ
ការងារទាំងឡាយដែលមានតម្រូវការនៅក្នុងប្រទេសបញ្ជូន ហើយប្រព័ន្ធវាយតម្លៃជំនាញជាផ្លូវការត្រូវបានបង្កើតឡើង
② ក្រុមគោលដៅ
អ្នកដែលបានជាប់ក្នុងការប្រឡងសរសេរ និងការធ្វើតេស្តអនុវត្តសម្រាប់ជំនាញពាណិជ្ជកម្មដែលបានកំណត់ជាដើម។

*បន្តសុពលភាពស្នាក់នៅ

○ត្រឡប់ទៅប្រទេសរបស់ខ្លួនជាបណ្តោះអាសន្ន (រយៈពេលចាប់ពី 1 ខែឡើងទៅ)
*ក្នុងរយៈពេល 1 ឆ្នាំមុន ឬក្រោយពេលចាប់ផ្តើមការបណ្តុះបណ្តាលបច្ចេកទេស (iii)

ឆ្នាំទី 3

ធ្វើតេស្តជំនាញពាណិជ្ជកម្ម (ថ្នាក់ទី 3) ឬធ្វើតេស្តវាយតម្លៃការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (កម្រិតជំនាញ)

○ ផ្លាស់ប្តូរ ឬទទួលបានស្ថានភាពស្នាក់នៅក្នុងប្រទេសជប៉ុន
ស្ថានភាពស្នាក់នៅក្នុងប្រទេសជប៉ុន៖ "ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (iii) ចំណុច (a), (b)"
① ការងារគោលដៅ
ដូចគ្នានឹងការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (ii) ការងារដែលត្រូវផ្ទេរ
(មិនរាប់បញ្ចូលការងារមួយចំនួន ដែលកម្មសិក្សាការីបច្ចេកទេសមិនត្រូវបានបណ្តុះបណ្តាល (iii))
② ក្រុមគោលដៅ
អ្នកដែលបានជាប់ក្នុងការប្រឡងសរសេរ និងការធ្វើតេស្តអនុវត្ត សម្រាប់ជំនាញដែលបានកំណត់ (ថ្នាក់ទី 3 ។ល។)
③ ស្ថាប័នគ្រប់គ្រង និងស្ថាប័នអនុវត្ត
ស្ថាប័នដែលបំពេញតាមលក្ខខណ្ឌពិសេសជាក់លាក់ និងត្រូវបានទទួលស្គាល់ថាអាចជឿទុកចិត្តបាន

(iii) ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស — ការបណ្តុះបណ្តាល

ឆ្នាំទី 4

*បន្តសុពលភាពស្នាក់នៅ

ឆ្នាំទី 5

ធ្វើតេស្តជំនាញពាណិជ្ជកម្ម (ថ្នាក់ទី 2) ឬធ្វើតេស្តវាយតម្លៃការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស (កម្រិតខ្ពស់)

○ត្រឡប់ទៅប្រទេសខ្លួនវិញ

# 3 ការងារទាក់ទងនឹងវិស័យកសិកម្ម និងរុក្ខាប្រមាញ់

បច្ចុប្បន្ននេះ ប្រភេទការងាaរចំនួន 91 និងប្រតិបត្តិការចំនួន 167 ត្រូវបានចុះជាប្រភេទការងារ និងប្រតិបត្តិការដែលត្រូវផ្ទេរ ដែលអាចឈានទៅកាន់ការបណ្ដុះបណ្ដាលផ្នែកបច្ចេកទេសដំណាក់កាល (ii) នៅក្នុងកម្មវិធីបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស។ ក្នុងចំណោមនោះ ប្រភេទការងារចំនួន 3 និងប្រតិបត្តិការចំនួន 7 ខាងក្រោម ត្រូវបានកំណត់ទាក់ទងនឹងវិស័យកសិកម្ម និងរុក្ខាប្រមាញ់។

ជាងនេះទៀត ស្តង់ដាសម្រាប់ការងារចាំបាច់ដែលត្រូវតែអនុវត្តដោយសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសសម្រាប់ប្រភេទការងារ និងប្រតិបត្តិការនីមួយៗ ត្រូវបានបង្កើតឡើង ហើយការងារដែលត្រូវការទាំងនេះត្រូវតែអនុវត្តយ៉ាងហោចណាស់ 50% នៃពេលវេលាក្នុងអំឡុងពេលបណ្ដុះបណ្ដាលបច្ចេកទេសនៅដំណាក់កាលនីមួយៗ ចាប់ពីដំណាក់កាល (i ) ដល់ដំណាក់កាល (iii) ។

## ទាក់ទងនឹងវិស័យកសិកម្ម និងរុក្ខាប្រមាញ់ (ប្រភេទការងារចំនួន 3 និងប្រតិបត្តិការចំនួន 7 គិតត្រឹមថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2024)

| ប្រភេទការងារ | ប្រតិបត្តិការ |
|---|---|
| ការដាំដុះដំណាំកសិកម្ម | ការសាកវប្បកម្មតាមទីតាំង |
| | ដាំដំណាំ/បន្លែលើដីទួល |
| | ការបណ្ដុះផ្លែឈើ |
| កសិកម្មចិញ្ចឹមសត្វ | ការចិញ្ចឹមជ្រូកសាច់ |
| | ការចិញ្ចឹមបសុបក្សី (ការប្រមូលពងមាន់) |
| | ផលិតផលទឹកដោះ |
| រុក្ខាសាស្ត្រ | ការដាំនិងបម្រុងព្រៃឈើ / ការបង្កើតសៀវភៅកំណត់ហេតុ |

*ការងារផ្នែករុក្ខាប្រមាញ់ត្រូវបានបន្ថែមពីថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2024 ។

សៀវភៅណែនាំនេះចាត់ទុកការងារកសិកម្មចិញ្ចឹមសត្វនិងការដាំដុះដំណាំកសិកម្មជា "ការងារទាក់ទងនឹងវិស័យកសិកម្ម"។

## ការធ្វើតេស្តជំនាញពាណិជ្ជកម្ម និងការពិនិត្យការវាយតម្លៃការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស

ការធ្វើតេស្តជំនាញពាណិជ្ជកម្ម និងការពិនិត្យកាវាយតម្លៃការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស ត្រូវបានធ្វើឡើងដើម្បីវាយតម្លៃជំនាញដែលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសទទួលបានសម្រាប់ប្រភេទការងារនីមួយៗនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេសនេះ។ សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសត្រូវតែទទួលកាធ្វើតេស្តដែលពាក់ព័ន្ធ និងបានជាប់ការធ្វើតេស្តដើម្បីឆ្លងទៅវគ្គបន្ទាប់ និងទទួលបានការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេសដំណាក់កាល (i) ទៅដំណាក់កាល (ii) ហើយបន្ទាប់មកទៅដំណាក់កាល (iii)។ ដូច្នេះ ត្រូវតែផ្ដល់ការណែនាំសមស្របដល់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសក្នុងការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេសប្រចាំថ្ងៃរបស់ពួកគេ ដើម្បីធានាថាពួកគេអាចទទួលបានជំនាញសមស្របទៅនឹងដំណាក់កាលនៃការបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេសដែលពួកគេកំពុងសិក្សា។

ការធ្វើតេស្តជំនាញពាណិជ្ជកម្មនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលកម្មសិក្សាការីបច្ចេកទេស មានកម្រិតមូលដ្ឋាន កម្រិតទី 3 កម្រិតទី 2 និងកម្រិតកម្រិតខ្ពស់។ សមាគមអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈខេត្ត (Prefectural Vocational Ability Development Associations) គឺជាអ្នកអនុវត្តការធ្វើតេស្តនេះ។ លើសពីនេះទៀត សម្រាប់ការបណ្ដុះបណ្ដាលប្រភេទស្ថាប័នគ្រប់គ្រង (Supervising-organization-type) ស្ថាប័នគ្រប់គ្រងត្រូវដាក់ពាក្យសុំធ្វើតេស្តតាមគេហទំព័រគាំទ្រនីតិវិធីតេស្ត (Testing Procedures Support Website) ដែលផ្ដល់ដោយស្ថាប័នបណ្ដុះបណ្ដាលបច្ចេកទេសផ្ទៃក្នុង (Organization for Technical Internal Training) (https://www.juken.otit.go.jp/) (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) ។

* សម្រាប់ការងារទាក់ទងនឹងវិស័យកសិកម្ម សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសត្រូវទទួលកាធ្វើតេស្តវាយតម្លៃជំនាញកសិកម្មដែលរៀបចំដោយសភាកសិកម្មជាតិ (National Chamber of Agriculture)។ លក្ខណសម្បត្តិនិងកម្រិតធ្វើតេស្តត្រូវបានបង្ហាញដូចខាងក្រោម៖

| កម្រិត | ប្រតិបត្តិការ | សេចក្ដីលម្អិតអំពីការធ្វើតេស្ត |
|---|---|---|
| កម្រិតដំបូង | សិក្ខាកាមដែលមានបទពិសោធន៍ជាក់ស្តែង ចាប់ពី 6 ខែឡើងទៅ | ជំនាញនិងចំណេះដឹងជាមូលដ្ឋានដែលត្រូវការ ដើម្បីអនុវត្តការងារជាមូលដ្ឋាន |
| កម្រិតមធ្យម | សិក្ខាកាមដែលមានបទពិសោធន៍ជាក់ស្តែង ចាប់ពី 12 ខែឡើងទៅ | ជំនាញនិងចំណេះដឹងដែលត្រូវការ ដើម្បីអនុវត្តការងារជាមូលដ្ឋាន |
| កម្រិតជំនាញ | សិក្ខាកាមដែលមានបទពិសោធន៍ជាក់ស្តែង ចាប់ពី 24 ខែឡើងទៅ | ជំនាញនិងចំណេះដឹងដែលកសិករកម្រិតដំបូងមានជាធម្មតា |
| កម្រិតខ្ពស់ | សិក្ខាកាមដែលមានបទពិសោធន៍ជាក់ស្តែង ចាប់ពី 48 ខែឡើងទៅ | ជំនាញនិងចំណេះដឹងដែលកសិករទូទៅមានជាធម្មតា |

**ចំណុចគន្លឹះ**

ថ្លៃសេវាដែលទាក់ទងនឹងការធ្វើតេស្តជំនាញពាណិជ្ជកម្ម និងការពិនិត្យការវាយតម្លៃការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស ត្រូវតែបង់ដោយស្ថាប័នអនុវត្ត ឬស្ថាប័នគ្រប់គ្រង ដោយផ្អែកលើ "គោលនយោបាយជាមូលដ្ឋានសម្រាប់ការអនុវត្តការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេសសមស្រប និងការការពារសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស (សេចក្តីជូនដំណឹងរបស់ក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព លេខ 1 ឆ្នាំ 2017)" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ)។

# 4 បណ្ណលំនៅឋាន

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស ដែលជាអ្នករស់នៅរយៈពេលមធ្យម និងរយៈពេលវែង តម្រូវឱ្យមានបណ្ណស្នាក់នៅជាប់ខ្លួនជានិច្ច ដែលជាគោលការណ៍ ផ្អែកលើមាត្រា 23 នៃច្បាប់ស្តីពីការគ្រប់គ្រងអន្តោប្រវេសន៍ និងការទទួលស្គាល់ជនភៀសខ្លួន (បទបញ្ជាគណៈរដ្ឋមន្ត្រី លេខ 319 ឆ្នាំ 1951 ដែលចាប់ពីពេលនេះទៅហៅកាត់ថា "ច្បាប់គ្រប់គ្រងអន្តោប្រវេសន៍")។ ការរក្សាទុកបណ្ណស្នាក់នៅដោយស្ថាប័នគ្រប់គ្រង និងស្ថាប័នអនុវត្ត ក៏ត្រូវបានហាមឃាត់ផងដែរ ដោយផ្អែកលើមាត្រា 48 នៃច្បាប់ស្តីពីការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេសសមស្រប និងការការពារសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស។

* អាចទទួលយកបានសម្រាប់និយោជិតរបស់ស្ថាប័នគ្រប់គ្រង ក្នុងការរក្សាទុកបណ្ណស្នាក់នៅបណ្តោះអាសន្នសម្រាប់នីតិវិធីផ្លូវច្បាប់ ដូចជាការផ្លាស់ប្តូរស្ថានភាពលំនៅឋាន ប៉ុន្តែរយៈពេលនៃការរក្សាទុកគួរតែត្រូវបានបង្រួមមកនៅកម្រិតអប្បបរមាតាមដែលអាចធ្វើទៅបាន។ លើសពីនេះទៀត សូមពិចារណាផងដែរអំពីការឆ្លើយតប ដូចជាការចេញបង្កាន់ដៃដើម្បីបញ្ជាក់កំណត់ត្រាច្បាស់លាស់មួយថាបណ្ណស្នាក់នៅត្រូវបានផ្ទេរតាមមធ្យោបាយណាមួយក្នុងចំណោមនិយោជិតនិងសិក្ខាកាម។




住居地 (ទីកន្លែងស្នាក់នៅ)
　ការផ្លាស់ប្តូរណាមួយត្រូវបានរាយនៅខាងខ្នងបណ្ណ។

就労制限の有無 (ការដាក់កំហិតការងារ)
　មិនអាចធ្វើសកម្មភាពការងារណាក្រៅពីការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេសឡើយ។

在留期間(満了日) (រយៈពេលស្នាក់នៅ (កាលបរិច្ឆេទផុតកំណត់))
　បង្ហាញរយៈពេលដែលសិក្ខាកាមស្នាក់នៅក្នុងប្រទេសជប៉ុន។

有効期間 (រយៈពេលនៃសុពលភាព)
　នេះជារយៈពេលសុពលភាពសម្រាប់បណ្ណស្នាក់នៅ។

資格外活動許可欄
(សកម្មភាពដែលបានអនុញ្ញាតក្រៅពីស្ថានភាពស្នាក់នៅដែលបានបញ្ជាក់)
　សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសមិនអាចទទួលបានការអនុញ្ញាតឱ្យធ្វើសកម្មភាពការងារក្រៅពីបានបញ្ជាក់នៅក្នុងស្ថានភាពស្នាក់នៅរបស់ខ្លួនឡើយ។

▶សូមមើលផ្នែក "តើបណ្ណស្នាក់នៅជាអ្វី?" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) នៃគេហទំព័ររបស់ទីភ្នាក់ងារសេវាអន្តោប្រវេសន៍ (Immigration Services Agency) សម្រាប់ព័ត៌មានលម្អិតអំពីរបៀបអានបណ្ណស្នាក់នៅ។
https://www.moj.go.jp/isa/applications/faq/newimmiact_4_point.html#anchor-point1

ចំណុចគន្លឹះ 1

## អ្នកអាចពិនិត្យសុពលភាពបណ្ណស្នាក់នៅ។

បញ្ចូលកន្លែងដែលតម្រូវឱ្យបំពេញព័ត៌មាន រួមទាំងលេខបណ្ណស្នាក់នៅផង លើផ្នែក "ការសាកសួរព័ត៌មានអំពីការផុតកំណត់លេខបណ្ណស្នាក់នៅ" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) នៃគេហទំព័ររបស់ទីភ្នាក់ងារសេវាអន្តោប្រវេសន៍ ដើម្បីពិនិត្យមើលថាតើលេខបណ្ណ ដែលបានបញ្ចូលបានផុតកំណត់ហើយឬនៅ។https://lapse-immi.moj.go.jp/ZEC/appl/e0/ZEC2/pages/FZECST011.aspx

ចំណុចគន្លឹះ 2

## រយៈពេលនៃសុពលភាពអាចនឹងខុសគ្នាពីអ្វីដែលបានបង្ហាញនៅខាងមុខបណ្ណ។

ជាទូទៅ រយៈពេលនៃសុពលភាពដែលបង្ហាញនៅខាងមុខបណ្ណ គឺជារយៈពេលសុពលភាពរបស់បណ្ណស្នាក់នៅ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើពាក្យសុំផ្លាស់ប្តូរស្ថានភាពលំនៅឋាន ឬពាក្យសុំពន្យាររយៈពេលស្នាក់នៅត្រូវបានដាក់ជូនមុនថ្ងៃផុតកំណត់រយៈពេលស្នាក់នៅដែលបង្ហាញនៅខាងមុខបណ្ណនោះ វានឹងបង្ហាញនៅខាងខ្នងបណ្ណស្នាក់នៅ ហើយបណ្ណនេះនឹងមានសុពលភាពរហូតដល់រយៈពេល 2 ខែបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់រយៈពេលស្នាក់នៅដែលបង្ហាញនៅខាងមុខបណ្ណ លុះត្រាតែមានការសម្រេចសម្រាប់ការដាក់ពាក្យសុំ។

## សូមបញ្ជាក់

ប្រសិនបើស្ថាប័នអនុវត្តអនុញ្ញាតឱ្យសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសធ្វើការក្រៅម៉ោងនៅស្ថាប័នអនុវត្តមួយផ្សេងទៀត (សម្រាប់ក្រុមហ៊ុន ឬបុគ្គល) ឬជួលជនបរទេសដោយគ្មានស្ថានភាពស្នាក់នៅដែលតម្រូវចាំបាច់ដើម្បីធ្វើការ ឬការអនុញ្ញាតឱ្យធ្វើសកម្មភាពការងារក្រៅពីបានបញ្ជាក់នៅក្នុងស្ថានភាពស្នាក់នៅរបស់ពួកគេ ស្ថាប័នអនុវត្តនោះអាចនឹងត្រូវបានចោទប្រកាន់ពីបទល្មើសផ្សព្វផ្សាយការងារខុសច្បាប់ (មាត្រា 73-2 នៃច្បាប់គ្រប់គ្រងអន្តោប្រវេសន៍)។ នៅពេលចាំបាច់ត្រូវពិនិត្យមើលស្ថានភាពស្នាក់នៅរបស់ជនបរទេស សូមទាក់ទងការិយាល័យសេវាអន្តោប្រវេសន៍ក្នុងតំបន់ដែលនៅជិតបំផុតរបស់អ្នក។

# 2 មូលដ្ឋានសុខភាពនិងសុវត្ថិភាព

*សៀវភៅណែនាំនេះរៀបរាប់អំពីច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម (ច្បាប់លេខ 57 ឆ្នាំ 1972) ជា "ច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម" និងបទបញ្ញត្តិស្តីពីសុខភាពនិងសុវត្ថិភាពឧស្សាហកម្ម (បទបញ្ជារបស់ក្រសួងការងារ លេខ 32 ឆ្នាំ 1972) ជា "បទបញ្ញត្តិសុខភាពនិងសុវត្ថិភាព"។

ច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម

- ① ការអប់រំនៅពេលជួលបុគ្គលិក មាត្រា 59 កថាខណ្ឌ (1)
- ② ការអប់រំនៅពេលប្រភេទការងារត្រូវបានផ្លាស់ប្តូរ មាត្រា 59 កថាខណ្ឌ (2)
- ③ ការអប់រំពិសេស មាត្រា 59 កថាខណ្ឌ (3)
- ការបណ្តុះបណ្តាលមេការ មាត្រា 60
- ការអប់រំសម្រាប់បុគ្គលិកដែលពាក់ពន្ធនឹងការងារគ្រោះថ្នាក់ឬការងារមានភយន្តរាយ មាត្រា 60-2

## ការអប់រំសុខភាពនិងសុវត្ថិភាពសម្រាប់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស

ដើម្បីឱ្យសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសអាចយល់កាន់តែច្បាស់អំពីការអប់រំសុខភាពនិងសុវត្ថិភាព ត្រូវបង្រៀនភាសាជប៉ុនធម្មតាឱ្យសិក្ខាកាមប្រើប្រាស់ នៅពេលឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់និងខុសប្រក្រតី ហើយប្រើប្រាស់រូបភាពនិងវីដេអូដែលងាយយល់។


















## ការអប់រំសុខភាពនិងសុវត្ថិភាពនៅពេលជួលបុគ្គលិក និងនៅពេលផ្លាស់ប្តូរប្រភេទការងារ

(មាត្រា 59 កថាខណ្ឌ (1) និង (2) នៃច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម)

អនុវត្តការអប់រំសុខភាពនិងសុវត្ថិភាពដោយមិនពន្យារពេលចំពោះបញ្ហាខាងក្រោម នៅពេលជួលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសថ្មី (បុគ្គលិក) និងនៅពេលដែលប្រភេទការងារត្រូវបានផ្លាស់ប្តូរ។

① បញ្ហាសំខាន់ៗដែលទាក់ទងនឹងគ្រោះថ្នាក់ ឬហានិភ័យនៃម៉ាស៊ីននិងវត្ថុធាតុដើម និងរបៀបគ្រប់គ្រងរបស់របរទាំងនេះ

② បញ្ហាសំខាន់ៗដែលទាក់ទងនឹងការប្រើប្រាស់ឧបករណ៍សុវត្ថិភាព ឧបករណ៍គ្រប់គ្រងសារធាតុគ្រោះថ្នាក់ ឬឧបករណ៍ការពារ និងរបៀបគ្រប់គ្រងឧបករណ៍ទាំងនេះ

③ បញ្ហាសំខាន់ៗដែលទាក់ទងនឹងនីតិវិធីផ្សេងៗ

④ បញ្ហាសំខាន់ៗដែលទាក់ទងនឹងការពិនិត្យនៅពេលចាប់ផ្តើមការងារ

⑤ បញ្ហាសំខាន់ៗដែលទាក់ទងនឹងមូលហេតុ និងការការពារជំងឺដែលអាចកើតមានឡើងពេលអនុវត្តការងារប្រភេទនេះ

⑥ បញ្ហាសំខាន់ៗដែលទាក់ទងនឹងការថែទាំ Seiri (បែងចែក), Seiton (ដាក់តាមលំដាប់លំដោយ) និង Seiketsu (មានស្តង់ដា)

⑦ បញ្ហាសំខាន់ៗដែលទាក់ទងនឹងវិធានការគ្រាអាសន្ន និងការវាយតម្លៃក្នុងពេលមានឧបទ្ទវហេតុ

⑧ បន្ថែមទៅនឹងព័ត៌មានដែលបានរាយក្នុងចំណុចមុនៗ គឺបញ្ហាណាមួយដែលត្រូវការសម្រាប់សុខភាព ឬសុវត្ថិភាពក្នុងការងារ

## ការអប់រំបណ្តុះបណ្តាលពិសេស

(មាត្រា 59 កថាខណ្ឌ (3) នៃច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម
(មាត្រា 36 នៃបទបញ្ញត្តិសុខភាពនិងសុវត្ថិភាព))

នៅពេលដែលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស (បុគ្គលិក) ត្រូវបានចាត់តាំងឱ្យធ្វើការងារដែលមានគ្រោះថ្នាក់ ឬមានភយន្តរាយមួយចំនួន ការអប់រំបណ្តុះបណ្តាលពិសេសទាក់ទងនឹងសុខភាព ឬសុវត្ថិភាពអំពីការងារនេះត្រូវតែអនុវត្ត។ ការអប់រំពិសេសត្រូវបានផ្តល់ដោយទីភ្នាក់ងារបណ្តុះបណ្តាលដែលបានចុះបញ្ជីដែលមានទីតាំងនៅតាមខេត្តនីមួយៗ។
ជាងនេះទៀត ប្រសិនបើមានបុគ្គលដែលមានចំណេះដឹង និងបទពិសោធន៍ជំនាញគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចនៅក្នុងក្រុមហ៊ុននោះ ការបណ្តុះបណ្តាលអាចត្រូវបានអនុវត្តនៅក្នុងក្រុមហ៊ុនដោយមានបុគ្គលរូបនេះជាអ្នកណែនាំ។
នៅទីនេះ យើងនឹងរាយបញ្ជីសម្ភារៈដែលទាក់ទងនឹងកសិកម្មជាចម្បងពីក្នុងចំណោមការងារដែលត្រូវការការអប់រំបណ្តុះបណ្តាលពិសេស។
ប្រសិនបើអ្នកចង់ដឹងបន្ថែម សូមមើលផ្នែក "ព័ត៌មានអំពីអាជ្ញាបណ្ណ គុណវុឌ្ឍិ វគ្គបណ្តុះបណ្តាលជំនាញ និងការអប់រំបណ្តុះបណ្តាលពិសេសទាក់ទងនឹងសុខភាពនិងសុវត្ថិភាពឧស្សាហកម្ម" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) នៅលើគេហទំព័ររបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព (https://www.mhlw.go.jp/stf/seisakunitsuite/bunya/roudoukijun/anzeneisei10/qualificaton_education.html) ។

[ការងារដោយប្រើរណាច្រវាក់ដើម្បីរំលំដើមឈើ កាត់មែកឈើធ្លាក់ចោល ឬច្រៀកដើមឈើ]



[ការងារបញ្ជារថយន្តលើកដាក់ទំនិញដែលមានបន្ទុកអតិបរមាតិចជាង 1 តោន]
[ការងារបញ្ជាត្រាក់ទ័រច្ចូកដី រថយន្តលើកដាក់ទំនិញដែលមានបន្ទុកអតិបរមាតិចជាង 1 តោន]
[ការងារបញ្ជាយានយន្តដឹកជញ្ជូននៅលើដីរដិបរដុបដែលមានសមត្ថភាពផ្ទុកអតិបរមាតិចជាង 1 តោន]
[ប្រតិបត្តិការគ្រឿងម៉ាស៊ីនសំណង់ប្រភេទយានយន្ត (សម្រាប់ពង្រាបដី។ល។)]
ការងារបញ្ជាគ្រឿងម៉ាស៊ីនសំណង់ប្រភេទយានយន្តតូចៗ (សម្រាប់ការពង្រាបដី ដឹកជញ្ជូន ផ្ទុក និងជីកកកាយ) ដែលមានទម្ងន់យានយន្ត <u>តិចជាង</u> 3 តោន* ដូចជា ត្រាក់ទ័រឈូសដី ត្រាក់ទ័រច្ចូកដី ត្រាក់ទ័រច្ចូកដីប្រើថាមពល ត្រាក់ទ័ររុញដីកង់ច្រវាក់ និងត្រាក់ទ័ររុញដីកង់កៅស៊ូ
* សិក្ខាកាមមិនអាចបញ្ជាយានយន្តទម្ងន់ 3 តោន ឬ<u>លើសពីនេះ</u> បានទេ លុះត្រាតែពួកគេបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញរួច។



[ការងារបញ្ជាម៉ាស៊ីនស្ទូចដែលអាចស្ទូចបានទម្ងន់តិចជាង 5 តោន]
[ការងារបញ្ជាម៉ាស៊ីនស្ទូចចល័តដែលអាចស្ទូចបានទម្ងន់តិចជាង 1 តោន]
[ការងារដែលពាក់ព័ន្ធនឹងការងាររអិលសម្រាប់រថយន្តស្ទូច ឬម៉ាស៊ីនស្ទូចចល័តដែលអាចស្ទូចបានទម្ងន់តិចជាង 1 តោន]



[ការងារទាក់ទងនឹងការដំឡើង រុះរើ ឬផ្លាស់ប្តូររន្ទា]

• បង្គង និងរន្ទារំកិល ត្រូវបានរួមបញ្ចូលនៅក្នុងពាក្យ "រន្ទា" ។

* ដោយហេតុថា មិនមានដែនកំណត់ចំពោះប្រភេទនៃរន្ទា និងកម្ពស់របស់វា ទីលានការងារដាច់ដោយឡែក និងចន្ទល់ដែលផ្គុំគ្នាជាផ្នែកតែមួយ ដូចបានបង្ហាញក្នុងរូបភាពនោះ ជាគោលការណ៍ត្រូវបានចាត់ទុកថាជារន្ទា និងតម្រូវឱ្យមានការអប់រំបណ្តុះបណ្តាលពិសេស។



[ការងារទាក់ទងនឹងការងារនៅកន្លែងគ្រោះថ្នាក់ដោយសារខ្វះអុកស៊ីសែន]

ការងារដែលធ្វើនៅក្នុងធុងសម្ពាធ (Silos) ឬរចនាសម្ព័ន្ធស្រដៀងគ្នា ដែលមិនសូវមានកំហាប់អុកស៊ីសែន




[ការអប់រំសុខភាពនិងសុវត្ថិភាពសម្រាប់អ្នកបញ្ជាម៉ាស៊ីនកាត់ស្មៅ*]

អ្នកដែលពាក់ព័ន្ធនឹងការងារដែលប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅ

* នេះគឺជាការអប់រំសុខភាពនិងសុវត្ថិភាព (ការអប់រំដែលអនុលោមតាមលក្ខខណ្ឌនៃការអប់រំបណ្តុះបណ្តាលពិសេស) ដោយផ្អែកតាមសេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព "ការអប់រំសុវត្ថិភាពនិងសុខភាពសម្រាប់អ្នកបញ្ជាម៉ាស៊ីនកាត់ស្មៅ (សេចក្តីជូនដំណឹងលេខ 66 ចុះថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2000)" (ឯកសារភាសាជប៉ុនតែប៉ុណ្ណោះ)



## ការងារដែលមានការដាក់កំហិត

(មាត្រា 61 នៃច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម)

នៅពេលដែលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសចូលរួមក្នុងការងារដែលមានការរឹតត្បិត (ការងារដែលត្រូវបានចែងដោយច្បាប់ស្តីពីសុខភាពនិងសុវត្ថិភាពឧស្សាហកម្ម ថាមានគ្រោះថ្នាក់ជាពិសេស ឬភយន្តរាយ) ពួកគេត្រូវតែបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ។
នៅទីនេះ យើងនឹងរាយបញ្ជីគ្រឿងបរិក្ខារដែលទាក់ទងនឹងវិស័យកសិកម្មជាចម្បងពីក្នុងចំណោមការងារដែលតម្រូវឱ្យសិក្ខាកាមត្រូវបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ។

### [ការបញ្ជារថយន្តលើកដាក់ទំនិញ]

ការងារបញ្ជារថយន្តលើកដាក់ទំនិញដែលមានបន្ទុកអតិបរមាចាប់ពី 1 តោនឡើងទៅ



### [ប្រតិបត្តិការគ្រឿងម៉ាស៊ីនសំណង់ប្រភេទយានយន្ត (សម្រាប់ពង្រាបដី។ល។)]

ការងារបញ្ជាគ្រឿងម៉ាស៊ីនសំណង់ប្រភេទយានយន្ត (សម្រាប់ការរានដី ដឹកជញ្ជូន ផ្ទុក និងជីកកកាយ) ដែលមានទម្ងន់យានយន្តចាប់ពី 3 តោនឡើងទៅ ដូចជា ត្រាក់ទ័រឈូសដី ត្រាក់ទ័រចូកដី ត្រាក់ទ័រចូកដីប្រើថាមពល ត្រាក់ទ័ររុញដីកង់ច្រវាក់ និងត្រាក់ទ័ររុញដីកង់កៅស៊ូ។

### [ការបញ្ជាត្រាក់ទ័រចូកដី]

ការងារបញ្ជាត្រាក់ទ័រចូកដី ឬរថយន្តលើកដាក់ទំនិញដែលមានបន្ទុកអតិបរមាចាប់ពី 1 តោនឡើងទៅ



### [ការបញ្ជាយានយន្តដឹកជញ្ជូននៅលើដីរដិបរដុប]

ការងារបញ្ជាយានយន្តដឹកជញ្ជូននៅលើដីរដិបរដុបដែលមានសមត្ថភាពផ្ទុកអតិបរមាចាប់ពី 1 តោនឡើងទៅ



### [ការបញ្ជារថយន្តស្ទូចចល័តធុនតូច]

រថយន្តស្ទូចចល័តដែលអាចស្ទូចបានទម្ងន់ចាប់ពី 1 តោន ដល់ទម្ងន់តិចជាង 5 តោន



## ការងារដែលតម្រូវឱ្យមានប្រធានប្រតិបត្តិការ

(មាត្រា 14 នៃច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម)

ការងារខាងក្រោម តម្រូវឱ្យចាត់តាំងប្រធានប្រតិបត្តិការ ហើយបុគ្គលនេះត្រូវតែទទួលបានអាជ្ញាបណ្ណ ឬបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ ដើម្បីធ្វើការជាប្រធានប្រតិបត្តិការ។

* ប្រធានប្រតិបត្តិការត្រូវតែត្រូវបានចាត់តាំងទៅតាមប្រភេទការងារសម្រាប់ការងារជាក់លាក់ដែលត្រូវតែគ្រប់គ្រង ដើម្បីការពារការរងរបួសឧស្សាហកម្ម ដោយផ្អែកលើមាត្រា 14 នៃច្បាប់សុខភាពនិងសុវត្ថិភាពឧស្សាហកម្ម។

នៅទីនេះ យើងនឹងរាយបញ្ជីគ្រឿងបរិក្ខារដែលពាក់ព័ន្ធនឹងការងារជាចម្បងទាក់ទងនឹងវិស័យកសិកម្ម។

### [ប្រធានប្រតិបត្តិការផ្នែកការគរទំនិញ]

ការងារដែលពាក់ព័ន្ធនឹងការដាក់ជង់ទំនិញ (ការគរ*) និងការផ្ទេរទំនិញ (ការបំបែក) ដែលមានកម្ពស់ចាប់ពី 2 ម៉ែត្រឡើងទៅ (មិនរាប់បញ្ចូលការងារដែលធ្វើឡើងដោយប្រើតែម៉ាស៊ីនលើកដាក់ទំនិញនោះទេ)។

* ការគរទំនិញសំដៅលើទំនិញដែលដាក់ជង់ក្នុងឃ្លាំង ក្នុងរោង ឬលើដី។ ទំនិញត្រូវបានវេចខ្ចប់ក្នុងថង់ ប្រអប់ ឬបាវ ហើយសូម្បីតែឈើក៏ស្ថិតនៅក្រោមប្រភេទនេះដែរ។

### [ប្រធានប្រតិបត្តិការការងារដែលខ្វះអុកស៊ីសែន]

សម្រាប់ការងារដែលធ្វើនៅក្នុងធុងសម្ភាធ (Silos) ឬរចនាសម្ព័ន្ធស្រដៀងគ្នាដែលមិនសូវមានកំហាប់អុកស៊ីសែន ត្រូវតែចាត់តាំងប្រធានប្រតិបត្តិការការងារគ្រោះថ្នាក់ដោយកង្វះអុកស៊ីសែន។

ដើម្បីធ្វើការជាប្រធានប្រតិបត្តិការប្រភេទនេះ បុគ្គលនោះត្រូវតែបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ សម្រាប់ប្រធានប្រតិបត្តិការគ្រោះថ្នាក់ដោយកង្វះអុកស៊ីសែន ឬវគ្គបណ្តុះបណ្តាលជំនាញសម្រាប់ប្រធានប្រតិបត្តិការគ្រោះថ្នាក់ដោយកង្វះអុកស៊ីសែន និងអ៊ីដ្រូសែនស៊ុលផួ។



## ការពាក់សម្លៀកបំពាក់ការងារនិងមួកសុវត្ថិភាព

ការពាក់សម្លៀកបំពាក់ត្រឹមត្រូវ គឺជាវិធានការដំបូងចំពោះសុវត្ថិភាព ដើម្បីការពារបុគ្គលិកពីគ្រោះថ្នាក់ការងារកសិកម្ម។ វាអាចមានបញ្ហា ប៉ុន្តែការស្លៀកពាក់ត្រឹមត្រូវនឹងធ្វើឱ្យការងារកាន់តែមានប្រសិទ្ធភាព។ ដូច្នេះហើយ ត្រូវជ្រើសរើសសម្លៀកបំពាក់ និងឧបករណ៍ការពារសមស្រប តាមប្រភេទការងារដែលអនុវត្តដោយសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស។

* ពាក់អាវដៃវែង និងខោជើងវែង (មិនមែនដៃអាវខ្លី ឬខោខ្លី) ដើម្បីការពាររបួសពីស្លឹកបន្លែ និងសត្វល្អិតទិចឬខាំ។



[មួកសុវត្ថិភាព]

ពាក់មួកសុវត្ថិភាពពេលធ្វើការនៅកន្លែងគ្រោះថ្នាក់ ដូចជាកន្លែងខ្ពស់ កន្លែងដែលមានកម្ទេចកម្ទីខ្ទាត កន្លែងដែលមានវត្ថុធ្លាក់ និងពេលធ្វើដំណើរតាមផ្លូវ។
ត្រូវប្រាកដថាខ្សែមួករឹតចង្កាមានសុវត្ថិភាពល្អ។



[ស្រោមដៃ]

ពាក់ស្រោមដៃការពារ នៅពេលធ្វើការងារដោយដៃដែលពាក់ព័ន្ធនឹងការប៉ះមុខកាំបិត ឬវត្ថុមុតស្រួច។



[វ៉ែនតាការពារ (វ៉ែនតាសម្រាប់ការពារភ្នែក)]

ពាក់វ៉ែនតាដើម្បីការពារភ្នែកនៅពេលពង្រាវ ឬបាញ់ថ្នាំសម្លាប់សត្វល្អិត ការពារពីកម្ទេចកម្ទីហុយ និងពីពន្លឺខ្លាំងអំឡុងពេលធ្វើការងារផ្សារដែក។



[ឧបករណ៍ចាប់ការធ្លាក់ (ដែលជារឿយៗសំដៅលើខ្សែក្រវាត់សុវត្ថិភាព)]

ប្រើឧបករណ៍ប្រភេទនេះដើម្បីការពារការធ្លាក់នៅពេលធ្វើការនៅកន្លែងខ្ពស់។
(រូបភាពបង្ហាញពីខ្សែក្រវាត់ពាក់ជុំវិញរាងកាយ)



[ឧបករណ៍ចុកត្រចៀក]

ប្រើពេលធ្វើការនៅកន្លែងដែលមានសំឡេងខ្លាំង។
មានឧបករណ៍ចុកត្រចៀក ឬប្រដាប់បិទត្រចៀក (ដែលគ្របស្លឹកត្រចៀក)។





[ស្បែកជើងកវែងសុវត្ថិភាព]

ពាក់ស្បែកជើងដែលមានក្បាលរឹងការពារមេជើង និងការពារការរអិល ពេលធ្វើការនៅកន្លែងដែលមានវត្ថុធ្ងន់អាចធ្លាក់ចុះ កន្លែងដែលមានកម្ទេចកម្ទីខ្ទាត និងកន្លែងដែលអាចនឹងឈរជំទើតចុងជើង ឬមានវត្ថុមុតស្រួច។



[ម៉ាស់ការពាឬធូលី និងម៉ាស់ការពារឧស្ម័ន]

ប្រើ "ម៉ាស់ការពារធូលី" នៅកន្លែងធ្វើការដែលមានធូលីច្រើនក្នុងបរិយាកាស និង "ម៉ាស់ខ្យល់" នៅតំបន់ដែលមានអុកស៊ីសែនទាប។ ប្រើម៉ាស់ការពារឧស្ម័ន ឬឧបករណ៍ការពារផ្លូវដង្ហើមមានកង្ហារអគ្គិសនី ដែលការពារឧស្ម័ននៅពេលបាញ់ថ្នាំសម្លាប់សត្វល្អិត។



## ស្លាកសញ្ញាសុវត្ថិភាព

ស្លាកសញ្ញាសុវត្ថិភាព គឺជាវិធីសាស្ត្រមួយដែលត្រូវបានប្រើប្រាស់ដើម្បីការពារការរងរបួសស្នាមក្នុងឧស្សាហកម្ម ព្រោះវាប្រើតួអក្សរ និងនិមិត្តសញ្ញាដើម្បីផ្តល់ជាមធ្យោបាយដែលអាចមើលឃើញយ៉ាងច្បាស់ក្នុងការជូនដំណឹងដល់មនុស្សអំពីការព្រមាន ឬការប្រុងប្រយ័ត្នទាក់ទងនឹងការងារគ្រោះថ្នាក់ និងតំបន់គ្រោះថ្នាក់ ហើយស្លាកសញ្ញាទាំងនោះធានាថា មនុស្សគោរពតាមវិធីប្រតិបត្តិការងារប្រកបដោយសុវត្ថិភាព។

ជាការល្អត្រូវបង្កើតស្លាកសញ្ញាសុវត្ថិភាពតាមស្តង់ដាអន្តរជាតិ ISO 7010:2019 ពីស្ថាប័នគំរូនីយកម្មអន្តរជាតិ (International Organization for Standardization) (និមិត្តសញ្ញាក្រាហ្វិក - ពណ៌សុវត្ថិភាព និងសញ្ញាសុវត្ថិភាព - ស្លាកសញ្ញាសុវត្ថិភាពដែលបានចុះបញ្ជី) និងស្តង់ដាឧស្សាហកម្មជប៉ុន JIS Z 8210:2017 (និមិត្តសញ្ញាព័ត៌មានសាធារណៈ ) ដើម្បីធានាថា មនុស្សគ្រប់គ្នាអាចយល់ពីអ្វីដែលស្លាកសញ្ញាទាំងនោះកំពុងពិពណ៌នា។

ជាងនេះទៀត ដូចបានបង្ហាញខាងក្រោម គឺជា "សញ្ញាសុវត្ថិភាពរួមដើម្បីការពារគ្រោះថ្នាក់នៅកន្លែងសាងសង់" ដែលបង្កើតឡើងដោយសមាគមសុខភាព និងសុវត្ថិភាពការងារសំណង់ជប៉ុន (Japan Construction Occupational Safety and Health Association - JCOSHA)។

មនុស្សគ្រប់គ្នាអាចប្រើប្រាស់ស្លាកសញ្ញាសុវត្ថិភាពទាំងនេះដោយមិនគិតថ្លៃ ដូច្នេះសូមប្រើវាជាភាសាបរទេស (ភាសាខ្មែរត្រូវបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម) ដែលបង្ហាញក្នុងផ្ទៃពណ៌សទទេខាងក្រោមរូបសញ្ញា ទៅតាមភាសាកំណើតរបស់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស។

សម្រាប់ព័ត៌មានលម្អិតអំពីរបៀបប្រើប្រាស់ពួកវា សូមមើលទំព័រ "ការណែនាំអំពីស្លាកសញ្ញាសុវត្ថិភាពរួមដើម្បីការពារគ្រោះថ្នាក់ក្នុងការងារសាងសង់" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) នៅលើគេហទំព័រ JCOSHA ។https://www.kensaibou.or.jp/safety_sign/index.html




































# 3 ការអនុវត្តសកម្មភាពសុខភាពនិងសុវត្ថិភាព

## ការអនុវត្ត 5S

5S គឺជាពាក្យដែលបង្កើតចេញពីអក្សរខាងដើមរបស់ពាក្យ Seiri (បែងចែក) Seiton (ដាក់តាមលំដាប់លំដោយ) Seisou (សម្អាត ថែទាំ) Seiketsu (មានស្តង់ដា) និង Shitsuke (មាននិរន្តរភាព)។ ការប្រឹងប្រែងធ្វើការងារដើម្បីសម្រេចបានអក្សរ 5S នេះជារៀងរាល់ថ្ងៃ គឺមានសារៈសំខាន់ក្នុងការការពារគ្រោះថ្នាក់ការងារ។

| | ការពន្យល់ | ឧទាហរណ៍ | ចម្លើយជាឧទាហរណ៍ |
|---|---|---|---|
| [Seiri (បែងចែក)]   | Seiri (បែងចែក) សំដៅលើការបែងចែកឧបករណ៍ដែលមិនចាំបាច់ចេញពីឧបករណ៍ដែលចាំបាច់ដើម្បីយកទៅបោះចោល។ | ប្រសិនបើទុកចោលឧបករណ៍ដែលមិនចាំបាច់នៅផ្លូវឆ្លងកាត់ បុគ្គលិកនឹងមិនត្រឹមតែធ្វើដំណើរ និងដួលលើឧបករណ៍ទាំងនេះប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យប្រសិទ្ធភាពការងារធ្លាក់ចុះទៀតផង។ | កំណត់នីតិវិធីដើម្បីបែងចែកឧបករណ៍ដែលមិនចាំបាច់។ |
| [Seiton (ដាក់តាមលំដាប់លំដោយ)]   | Seiton (ដាក់តាមលំដាប់លំដោយ) សំដៅលើរបៀបដាក់របស់របរ ដូចជាឧបករណ៍ដែលត្រូវការសម្រាប់ការងារ កន្លែងទុកដាក់ឧបករណ៍ទាំងនេះ និងរបៀបរៀបចំពួកវា ដើម្បីឱ្យអាចប្រើប្រាស់បាននៅពេលចាំបាច់។ | ប្រសិនបើរៀបចំទុកដាក់ឧបករណ៍តាមលំដាប់លំដោយទេនោះ វានឹងមិនអាចរកឃើញឧបករណ៍ដែលត្រូវការបានឡើយ ដែលនាំឱ្យបុគ្គលិកត្រូវចំណាយពេលច្រើនក្នុងការស្វែងរកឧបករណ៍។ | ចូរសម្អាតនៅក្រោយនៅពេលបញ្ចប់ការងារ ដើម្បីកុំឱ្យឧបករណ៍ណាមួយនៅសល់រាយប៉ាយជុំវិញនោះ។ |
| [Seisou (សម្អាត ថែទាំ)]  | Seisou (សម្អាត ថែទាំ) សំដៅលើការសម្អាត និងយកសំរាមចេញពីគ្រឿងចក្រនិងបរិក្ខារ ឃ្លាំងនិងកន្លែងធ្វើការ ព្រមទាំងការសម្អាតធូលីចេញពីសម្លៀកបំពាក់និងរបស់របរស្រដៀងគ្នានោះ។ | ការមិនសម្អាតសំរាម ឬធូលី អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដែលនាំឱ្យបុគ្គលិករអិលដួលដោយមិននឹកស្មានដល់។ | សម្អាតកន្លែងធ្វើការឱ្យបានទៀងទាត់ និងបោសធូលីចេញពីសម្លៀកបំពាក់ធ្វើការមួយថ្ងៃម្តង ដូចជានៅពេលបញ្ចប់ការងារជាដើម។ |
| [Seiketsu (មានស្តង់ដា)]  | Seiketsu (មានស្តង់ដា) សំដៅលើការរក្សាកម្រិតល្អនៃការបែងចែក (Seiri) ការដាក់តាមលំដាប់លំដោយ (Seiton) និង ការសម្អាតថែទាំ (Seisou) ហើយធានាថា រាងកាយបុគ្គលិក សម្លៀកបំពាក់ និងកន្លែងជុំវិញរបស់ ពួកគេស្អាត។ | នៅពេលរៀបចំអាហារដូចជាបន្លែជាដើម ប្រសិនបើរទេះផ្ទុកមិនត្រូវបានសម្អាតញឹកញាប់គ្រប់គ្រាន់ទេ វានឹងបង្កបញ្ហាទាក់ទងនឹងអនាម័យ។ | ពិចារណា និងអនុវត្តគំនិតផ្តួចផ្តើមដែលដឹកនាំដោយក្រុមអ្នកគ្រប់គ្រង ដើម្បីរក្សាលក្ខខណ្ឌស្តង់ដានៅកន្លែងធ្វើការ។ |
| [Shitsuke (មាននិរន្តរភាព)]  | Shitsuke (មាននិរន្តរភាព) សំដៅលើការបង្កើតច្បាប់ និងបង្កើតទម្លាប់ដើម្បីអនុវត្តឱ្យបានហ្មត់ចត់នូវអក្សរ 4S ដែលមានដូចជា Seiri (បែងចែក) Seiton (ដាក់តាមលំដាប់លំដោយ) Seisou (សម្អាត ថែទាំ) និង Seiketsu (មានស្តង់ដា) ។ | ប្រសិនបើមិនផ្តល់ការអប់រំ ឬការណែនាំជាទៀងទាត់ទេ វាមានហានិភ័យដែលថា ច្បាប់ដែលបានបង្កើតឡើងនឹងមិនត្រូវបានអនុវត្តឱ្យបានហ្មត់ចត់ឡើយ។ | និយោជិតទាំងអស់គួរតែបង្កើតទម្លាប់មួយ ដើម្បីអនុវត្តតាមច្បាប់ដែលបានបង្កើតឡើងទាំងនោះ។ |

## 5S គឺជាវិធានការណ៍ដំបូងដើម្បីសុវត្ថិភាព

[ចំណុចគន្លឹះសម្រាប់ការរក្សាទុក]

① កន្លែងដែលឧបករណ៍មិនត្រូវរក្សាទុក

- កុំទុកដាក់ឧបករណ៍នៅក្នុងផ្លូវឆ្លងកាត់ ច្រកចូល ច្រកចេញ ច្រកចេញគ្រាមានអាសន្ន និងនៅលើជណ្តើរ។





- កុំទុកដាក់ឧបករណ៍ជុំវិញគ្រឿងចក្រ ឬនៅពីមុខប្រអប់កុងតាក់ ក្បាលបំពង់ទឹកឬឧបករណ៍ពន្លត់អគ្គីភ័យ។




② រក្សាសុវត្ថិភាពទីតាំងរក្សាទុក និងបង្កើតវិធីរក្សាទុក

- រក្សាលំហដែលចាំបាច់ដើម្បីរក្សាទុកឧបករណ៍ផ្សេងៗដូចជា គ្រឿងចក្រនិងឧបករណ៍កសិកម្ម ហើយទុកដាក់ឧបករណ៍ទាំងនេះនៅទីតាំងដែលបានកំណត់ (ទីតាំង) ដោយប្រើវិធីរក្សាទុកដែលបានកំណត់។ សូមពិចារណាផងដែរ ដើម្បីធានាថា តំបន់នោះមានពន្លឺនិងខ្យល់ចេញចូលគ្រប់គ្រាន់។
- គោរពតាមច្បាប់ទាក់ទងនឹងទីតាំងរក្សាទុកដែលបានកំណត់ របៀបរក្សាទុក និងដាក់ជង់គរលើគ្នា។



③ អនុវត្តការរក្សាទុកទៅតាមរូបរាង

- ឧបករណ៍វែងៗត្រូវតែរក្សាទុកដោយផ្តេក មិនត្រូវផ្អែកទៅជញ្ជាំង ហើយឧបករណ៍មូលៗដែលអាចនឹងជារមៀល ត្រូវតែរក្សាទុកដោយប្រើឧបករណ៍ទប់ ដូចជាស្នៀតជាដើម។



- នៅពេលដាក់ឧបករណ៍វែងៗផ្អែកនឹងជញ្ជាំង ត្រូវចងវាដោយខ្សែពួរ ហើយដាក់ឱ្យនឹងជាប់ជញ្ជាំង ដើម្បីកុំឱ្យវាធ្លាក់លើ។



• ប៉ែលត្រូវតែព្យួរឬ
ទុកដាក់ឱ្យនឹងជាប់ជញ្ជាំង។





④ ការរក្សាទុកតាមការប្រើប្រាស់ជារឿយៗ

• ពេលគិតគូរអំពីភាពញឹកញាប់នៃការប្រើប្រាស់ ត្រូវតែទុកឧបករណ៍ដែលប្រើញឹកញាប់នៅទីតាំងដែលងាយស្រួលយកមកប្រើវិញ។



⑤ របៀបរក្សាទុកឧបករណ៍ដែលមានមុខមុត

• គ្របមុខរបស់វា នៅពេលទុកដាក់ឧបករណ៍ទាំងនេះ។



## សកម្មភាពព្យាករណ៍ហានិភ័យ (សកម្មភាព KY) និងការប្រជុំអំពីប្រអប់ឧបករណ៍ (TBM)

[សកម្មភាព KY]
ការព្យាករណ៍ហានិភ័យ (K៖ Kiken, Y៖ Yochi) សកម្មភាពព្យាយាមការពារការរងរបួសឧស្សាហកម្ម ដោយឱ្យបុគ្គលិកពិភាក្សាគ្នាអំពីហានិភ័យដែលអាចកើតមាននៅកន្លែងធ្វើការ និងនៅក្នុងការងារដែលពួកគេធ្វើ ព្រមទាំងការរងរបួសឧស្សាហកម្មដែលកើតឡើងពីហានិភ័យទាំងនេះ ដើម្បីឱ្យបុគ្គលិកអាចអនុវត្តការងាររបស់ពួកគេដោយការយល់ដឹងខ្ពស់អំពីគ្រោះថ្នាក់ជាក់លាក់។ សកម្មភាពប្រភេទនេះក៏ត្រូវបាននិយាយសំដៅជាញឹកញាប់ថាជា "KYK" (Kiken Yochi Katsudou) ។

[TBM]
រៀងរាល់ថ្ងៃ មុនពេលចាប់ផ្ដើមការងារ ត្រូវរៀបចំកិច្ចប្រជុំមួយ ដើម្បីស្វែងយល់ថាតើការងារត្រូវធ្វើនៅថ្ងៃណា មានគ្រោះថ្នាក់អ្វីខ្លះដែលពាក់ព័ន្ធ និងផ្ដល់ការណែនាំការងារឱ្យបានហ្មត់ចត់។ ការប្រជុំអំពីប្រអប់ឧបករណ៍ (TBM) គឺជាការប្រជុំមួយដែលបុគ្គលិកពិភាក្សាអំពី "ប្រភេទនៃការងារ" និង "ចែករំលែកព័ត៌មានអំពីគ្រោះថ្នាក់ណាមួយ" មុនពេលចាប់ផ្ដើមការងារ។

គ្រោះថ្នាក់កើតឡើងនៅពេលដែលស្ថានភាពចំនួន 2 គឺ "ស្ថានភាពមិនមានសុវត្ថិភាព" និង "អាកប្បកិរិយាគ្មានសុវត្ថិភាព" កើតមានជាមួយគ្នា។ ដូច្នេះហើយ ត្រូវលុបបំបាត់ "អាកប្បកិរិយាគ្មានសុវត្ថិភាព" ដែលបង្កឡើងដោយមនុស្ស នៅពេលដែលពួកគេធ្វើសកម្មភាពប្រកបដោយគ្រោះថ្នាក់ ដូចជាវិធីដែលពួកគេធ្វើការ ឬប្រសិនបើពួកគេធ្វេសប្រហែស។



# 4 ការធានាសុវត្ថិភាពសម្រាប់គ្រឿងយន្តកសិកម្ម

## ការកើតឡើងនូវគ្រោះថ្នាក់ក្នុងការងារកសិកម្ម

យោងតាមឯកសារដែលចេញផ្សាយដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ភាគរយនៃការស្លាប់ដោយសារគ្រោះថ្នាក់ក្នុងការងារកសិកម្ម (ចំនួនគ្រោះថ្នាក់ដល់ជីវិតក្នុងចំណោមមនុស្ស 100 ពាន់នាក់ក្នុងអំឡុងឆ្នាំ 2022) គឺខ្ពស់ជាងមធ្យមភាគនៃឧស្សាហកម្មទាំងអស់ចំនួន 9 ដង ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វ 1 ខាងក្រោម។

ជាងនេះទៅទៀត បើពិនិត្យលើការវិភាគឧបទ្ទវហេតុដែលបណ្តាលឱ្យស្លាប់ដោយមូលហេតុ (សរុបចំនួន 238 នាក់) មានអ្នកស្លាប់ដោយសារត្រាក់ទ័រដឹកអ្នកដំណើរចំនួន 62 នាក់ អ្នកស្លាប់ដោយសារគោយន្តភ្ជួរដីចំនួន 21 នាក់ និងយានជំនិះដឹកជញ្ជូនផ្នែកកសិកម្មចំនួន 16 នាក់ ស្មើនឹង 41.6% នៃចំនួនអ្នកស្លាប់សរុបដូចមានបង្ហាញក្នុងក្រាហ្វ 2 ខាងក្រោម។ ពេលរាប់បញ្ចូលអ្នកស្លាប់ដែលពាក់ព័ន្ធនឹងគ្រឿងយន្តកសិកម្ម ដូចជាម៉ាស៊ីនកាត់ស្មៅជាដើម ទៅនឹងតួលេខនេះ ភាគរយគឺមានចំនួន 63.9% ។

### ក្រាហ្វ 1៖ បម្រែបម្រួលចំនួនគ្រោះថ្នាក់ដល់ជីវិតក្នុងចំណោមបុគ្គលិកនិយោជិត 100 ពាន់នាក់




ប្រភពឯកសារយោងសម្រាប់ទិន្នន័យចំនួនការស្លាប់
កសិកម្ម៖
ការស្ទង់មតិគ្រោះថ្នាក់ដល់ជីវិតក្នុងការងារកសិកម្ម (Agricultural Work Fatal Accidents Survey) (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
ឧស្សាហកម្មផ្សេងទៀត៖
របាយការណ៍គ្រោះថ្នាក់ដល់ជីវិត (Fatal Accidents Report) (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) (ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព)
ប្រភពឯកសារយោងសម្រាប់ទិន្នន័យចំនួនបុគ្គលិកនិយោជិត
កសិកម្ម៖
ជំរឿនកសិកម្ម និងរុក្ខាប្រមាញ់ (Census of Agriculture and Forestry) ការស្ទង់មតិអំពីចលនានៃរចនាសម្ព័ន្ធកសិកម្ម (Survey on Movement of Agricultural Structure) (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
ឧស្សាហកម្មផ្សេងទៀត៖
ការស្ទង់មតិកម្លាំងពលកម្ម (Labour Force Survey) (ក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង)

### ក្រាហ្វ 2៖ ការកើតឡើងនូវគ្រោះថ្នាក់ដល់ជីវិតតាមមូលហេតុ (ឆ្នាំ 2022)




ប្រភព៖ ឯកសារផ្សព្វផ្សាយដោយការិយាល័យផលិតកម្មដំណាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ 2024
https://www.maff.go.jp/j/press/nousan/sizai/240222.html

## វិធានការដាក់លាក់សម្រាប់ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស

① ក្នុងអំឡុងពេលបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស ស្ថាប័នអនុវត្តគួរតែដឹងអំពីសមត្ថភាពរបស់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសរបស់ខ្លួន កំណត់ឱ្យបានច្បាស់លាស់ ថាតើគ្រឿងម៉ាស៊ីន និងបរិក្ខារណាខ្លះដែលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសម្នាក់ៗអាចប្រើបាន ឬមិនអាចប្រើបាន ហើយបន្ទាប់មក ត្រូវជូនដំណឹងឱ្យបានហ្មត់ចត់ដល់សិក្ខាកាម និងបុគ្គលិកនិយោជិតផ្សេងទៀតដែលធ្វើការជាមួយសិក្ខាកាមទាំងនោះអំពីបញ្ហានេះ ដើម្បីឱ្យសិក្ខាកាមកម្មសិក្សាករីបច្ចេកទេសអាចទទួលបានចំណេះដឹងផ្នែកគ្រឿងម៉ាស៊ីននិងបរិក្ខារស្របតាមផែនការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស។

ពេលធ្វើការជាមួយគ្រឿងម៉ាស៊ីន អ្នកគ្រប់គ្រងបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស និងគ្រូបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេសត្រូវផ្តល់ការណែនាំសមស្រប ដើម្បីធានាថាសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសអាចធ្វើការងារដោយសុវត្ថិភាព។ វាក៏មានប្រសិទ្ធភាពផងដែរក្នុងការផ្តល់ការណែនាំដូចជាការអនុញ្ញាតឱ្យសិក្ខាកាមចាប់ផ្តើមដោយប្រើប្រាស់គ្រឿងម៉ាស៊ីនដែលមានហានិភ័យទាប។ ឧទាហរណ៍ នៅពេលកាត់ស្មៅ អាចប្រើវិធីសាស្ត្រផ្សេងៗឱ្យសិក្ខាកាមប្រើតែម៉ាស៊ីនកាត់ស្មៅដែលមានហានិភ័យទាប ដែលមានផ្លែកាត់ជាខ្សែនីឡុង នៅពេលដែលពួកគេនៅតែមិនស្គាល់ការងារនៅឡើយ។



ផ្លែកាត់ជាខ្សែនីឡុង

② នៅពេលបើកវគ្គបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស និងអនុញ្ញាតឱ្យសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសបញ្ជាគ្រឿងយន្តកសិកម្ម ពួកគេត្រូវតែមានអាជ្ញាប័ណ្ណជាចាំបាច់។ ឧទាហរណ៍ បណ្ណបើកបរ (បណ្ណបើកបរយានយន្តធុនតូចពិសេស ឬបណ្ណបើកបរយានយន្តធុនធំពិសេស) ពិតជាចាំបាច់ ក្រោមច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីបើកបរគ្រឿងយន្តកសិកម្មដូចជា ត្រាក់ទ័រ ម៉ាស៊ីនច្រូតកាត់ និងរថយន្តលើកដាក់ទំនិញតាមផ្លូវសាធារណៈ។ ដូចគ្នានេះដែរ សិក្ខាកាមត្រូវតែបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ ឬការអប់រំបណ្តុះបណ្តាលពិសេសដោយអនុលោមតាមច្បាប់ស្តីពីសុខភាពនិងសុវត្ថិភាពឧស្សាហកម្ម សូម្បីតែនៅពេលបើកបរ ឬបញ្ជារថយន្តលើកដាក់ទំនិញនៅទីតាំងឯកជន ដូចជានៅលើដីដាំដុះ ឬនៅក្នុងឃ្លាំងជាដើម។ សូមប្រាកដថា សិក្ខាកាមទទួលបានការបង្រៀនអំពីសុវត្ថិភាពសម្រាប់បញ្ជាត្រាក់ទ័រ និងយានយន្តស្រដៀងគ្នា បើទោះជាពួកគេបញ្ជាយានយន្តទាំងនោះតែក្នុងទីតាំងកម្មសិទ្ធិឯកជនក៏ដោយ។ ព័ត៌មានអំពីកន្លែងដែលការបង្រៀនទាំងនេះអាចធ្វើឡើងបាន គឺពីសាកលវិទ្យាល័យកសិកម្មដែលនៅជិតបំផុតរបស់អ្នក មជ្ឈមណ្ឌលប្រឹក្សាគាំទ្រប្រចាំខេត្ត (Prefectural Extension Advisory Center) សហករណ៍កសិកម្មជប៉ុន (Japan Agricultural Cooperatives - JA) ឬហាងលក់ឧបករណ៍និងបរិក្ខារកសិកម្ម។

## ការធានាសុវត្ថិភាពសម្រាប់គ្រឿងម៉ាស៊ីន និងបរិក្ខារផលិតផលកសិកម្ម

ឧបទ្ទវហេតុដែលពាក់ព័ន្ធនឹងសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស កំពុងក្លាយជាបញ្ហាទូទៅដោយសារគ្រឿងម៉ាស៊ីននិងបរិក្ខារដែលប្រើសម្រាប់រៀបចំ តម្រៀប និងវេចខ្ចប់ផលិតផលកសិកម្ម (ហៅកាត់ថា "គ្រឿងម៉ាស៊ីន និងបរិក្ខារផលិតផលកសិកម្ម")។

វិធានការសុវត្ថិភាពសម្រាប់ឧបទ្ទវហេតុទាំងនេះមានដូចខាងក្រោម។

① ធានាសុវត្ថិភាពសម្រាប់តួសំខាន់នៃគ្រឿងបរិក្ខារ

ពិនិត្យមុនពេលចាប់ផ្តើមការងារ ដើម្បីឱ្យដឹងថា គម្របការពារត្រូវបានដំឡើងនៅផ្នែកមានចលនា ដូចជា ច្រវាក់ និងប្រអប់លេខ ហើយថាឧបករណ៍សុវត្ថិភាព ដូចជាប៊ូតុងពន្លត់ម៉ាស៊ីនបន្ទាន់ មានដំណើរការត្រឹមត្រូវ។






② ពិនិត្យនិងសម្អាត
នៅពេលដែលគ្រឿងម៉ាស៊ីន និងបរិក្ខារផលិតផលកសិកម្មមិនដំណើរការត្រឹមត្រូវ វាអាចបណ្ដាលឱ្យមានគ្រោះថ្នាក់។ ដូច្នេះ ត្រូវសម្អាតដោយប្រុងប្រយ័ត្ន ដាក់ប្រេងរំអិល និងជំនួសផ្នែកចាស់ៗនៃគ្រឿងម៉ាស៊ីន និងបរិក្ខារ។
ម្យ៉ាងទៀត ជានិច្ចកាលត្រូវរៀបចំឱ្យមានរបៀបរៀបរយ និងសម្អាតកំរាលឥដ្ឋជុំវិញគ្រឿងម៉ាស៊ីននិងបរិក្ខារ ពីព្រោះខ្សែភ្លើងនិងវត្ថុតូចៗនៅលើកំរាលឥដ្ឋ អាចបណ្ដាលឱ្យមនុស្សធ្វើដំណើរ និងជំពប់ជើងដួល។

③ ធានាសុវត្ថិភាពក្នុងអំឡុងពេលការងារមិនជាប្រចាំ
ពេលក្រឡេកមើលឧទាហរណ៍អំពីគ្រោះថ្នាក់ពាក់ព័ន្ធនឹងសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស មានឧទាហរណ៍ជាច្រើន ដែលសិក្ខាកាមជាប់ដៃរបស់ខ្លួននៅខាងក្នុងគ្រឿងម៉ាស៊ីននៅពេលសម្អាត ឬពេលដកវត្ថុស្ទះចេញពីម៉ាស៊ីន។ ឧបទ្ទវហេតុប្រភេទនេះ អាចកើតឡើងយ៉ាងងាយស្រួលក្នុងអំឡុងពេលការងារមិនជាប្រចាំ ដូចជា នៅពេលមានបញ្ហាជាមួយគ្រឿងម៉ាស៊ីននិងបរិក្ខារកសិកម្មជាដើម។
នៅពេលដាក់ដៃរបស់អ្នកនៅជិតផ្នែកដែលមានចលនា ឬផ្នែកដែលវិល ដំបូងត្រូវប្រាកដថា អ្នកបិទភ្លើងម៉ាស៊ីននិងឧបករណ៍នោះ បន្ទាប់មកបិទកុងតាក់ផ្គត់ផ្គង់ថាមពលផ្សេងទៀត ឬដកខ្សែថាមពលភ្លើងចេញ ដើម្បីធានាថាម៉ាស៊ីននិងបរិក្ខារពិតជានឹងគ្មានចលនា។
ដើម្បីធានាថាបុគ្គលិកផ្សេងទៀតដែលនៅក្បែរនោះមិនប៉ះកុងតាក់ភ្លើង សូមជូនដំណឹងដល់ពួកគេដោយពន្យល់ថាអ្នកកំពុង "ដោះស្រាយបញ្ហាម៉ាស៊ីនឬបរិក្ខារ" នោះ ហើយក៏បង្ហាញសញ្ញាដែលបញ្ជាក់ថាម៉ាស៊ីន ឬបរិក្ខារកំពុង "ស្ថិតក្រោមការត្រួតពិនិត្យ"។



Seiri Seiton (បែងចែក & ដាក់តាមលំដាប់លំដោយ) គឺមានសារៈសំខាន់ ហើយត្រូវតែយកចិត្តទុកដាក់យកចិត្តទុកដាក់ជាពិសេសលើកម្រាលឥដ្ឋ។



# ការធានាសុវត្ថិភាពសម្រាប់ម៉ាស៊ីនកាត់ស្មៅ

គ្រោះថ្នាក់ទាក់ទងនឹងត្រាក់ទ័រគឺជាមូលហេតុទូទៅបំផុតនៃគ្រោះថ្នាក់ដល់ជីវិត ក្នុងវិស័យកសិកម្មហើយនៅពេលដែលយើងរាប់បញ្ចូលការរងរបួសក្នុងចំនួនឧបទ្ទវហេតុទាំងនេះ ភាគច្រើនបណ្ដាលមកពីម៉ាស៊ីនកាត់ស្មៅ។ វិធានការសុវត្ថិភាពសម្រាប់ម៉ាស៊ីនកាត់ស្មៅ មានដូចខាងក្រោម៖

① ការអប់រំសុខភាពនិងសុវត្ថិភាព

បុគ្គលិកត្រូវតែទទួលបានការអប់រំទាក់ទងនឹងសុវត្ថិភាព ដើម្បីប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅ។
នេះត្រូវបានកំណត់នៅក្នុងសេចក្ដីជូនដំណឹងរបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព "ការអប់រំសុខភាពនិងសុវត្ថិភាពសម្រាប់អ្នកបញ្ជាម៉ាស៊ីនកាត់ស្មៅ (សេចក្ដីជូនដំណឹងលេខ 66 ចុះថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ 2000)" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) ដែលក្នុងនោះមានបង្ហាញកម្មវិធីសិក្សាអំពីការអប់រំសុខភាពនិងសុវត្ថិភាព។

② ការជ្រើសរើសម៉ាស៊ីនកាត់ស្មៅ

ប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅដែលសមរម្យសម្រាប់គោលបំណងនៃការងារកសិកម្មទាក់ទងនឹងរូបរាងរបស់ម៉ាស៊ីនកាត់ស្មៅ និងទិន្នផលរបស់វា។
សូមប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅដែលមានវិញ្ញាបនបត្រត្រួតពិនិត្យសុវត្ថិភាពជាស្តង់ដា ដើម្បីកំណត់សុវត្ថិភាពរបស់ម៉ាស៊ីនកាត់ស្មៅ។
ទន្ទឹមគ្នានេះ នៅពេលណាដែលអាចធ្វើទៅបាន សូមជ្រើសរើសប្រភេទម៉ាស៊ីនកាត់ស្មៅដែលបន្ថយល្បឿនដោយស្វ័យប្រវត្តិ នៅពេលដែលអ្នកបញ្ជាដកដៃរបស់ខ្លួនចេញពីដងម៉ាស៊ីនកាត់ស្មៅ។

<ឧទាហរណ៍អំពីវិញ្ញាបនបត្រត្រួតពិនិត្យសុវត្ថិភាព>

(ចំណាំ) NARO គឺជាអក្សរកាត់របស់ស្ថាប័នស្រាវជ្រាវចំណីអាហារនិងកសិកម្មជាតិ (National Agriculture and Food Research Organization) ។ ដោយសារគ្រោះថ្នាក់ការងារកសិកម្មឥតឈប់ឈរ ប្រព័ន្ធចាស់នៃការត្រួតពិនិត្យប្រភេទ និងការវាយតម្លៃ សុវត្ថិភាពសម្រាប់គ្រឿងយន្តកសិកម្មត្រូវបានលុបចោល ហើយគ្រោងការណ៍ត្រួតពិនិត្យសុវត្ថិភាពថ្មីមួយ (គ្រោងការណ៍បន្ទាប់បន្សំ) ត្រូវបានណែនាំឱ្យអនុវត្តចាប់ពីឆ្នាំសារពើពន្ធ 2018 មក។ សម្រាប់ព័ត៌មានលម្អិត សូមមើលគេហទំព័រ NARO ។

https://www.naro.go.jp/laboratory/iam/contents/test/index.html

③ ការត្រួតពិនិត្យ ថែទាំ និងការលៃតម្រូវ

ផ្លែកាត់ត្រូវបានប្រើជាសំខាន់ដើម្បីកាត់ ព្រោះវាអាចប្រើប្រាស់បានច្រើនមុខ។
ផ្លែកាត់គួរតែត្រូវបានពិនិត្យរកមើលការខូចខាត ឬខូចទ្រង់ទ្រាយណាមួយ ព្រោះថាចុងរបស់មុខផ្លែកាត់អាចបែកចេញ ហើយហើរឡើងលើអាកាស។
នៅពេលកាត់ជិតរបង និងដើមឈើបញ្ឈរ ត្រូវប្រើផ្លែកាត់ជាខ្សែនីឡុង ព្រោះវាមិនមានគ្រោះថ្នាក់ខ្លាំងទេ ប្រសិនបើផ្លែប្រភេទនេះប៉ះនឹងរបង ឬដើមឈើ។



ម៉ាស៊ីនកាត់ដែក

ការដោះចេញ ឬផ្លាស់ប្ដូរគម្របការពារកម្ទេចកម្ទីហើរដែលនៅជិតផ្លែកាត់ ដោយសារស្មៅងាយទាក់ជាប់ គឺមិនសមស្របទេ។
សម្រាប់ម៉ាស៊ីនកាត់ស្មៅដែលមានខ្សែស្ពាយនៅស្មា សូមលៃតម្រូវប្រវែងខ្សែស្ពាយឱ្យត្រូវនឹងរាងកាយរបស់អ្នក។
ជាងនេះទៀត ត្រូវសម្អាតនិងត្រួតពិនិត្យផ្លែជានិច្ច បន្ទាប់ពីប្រើប្រាស់រួច។



④ ឧបករណ៍ការពារនិងសម្លៀកបំពាក់

ពាក់វ៉ែនតាការពារ ឬរបាំងមុខដើម្បីការពារភ្នែករបស់អ្នក។
ក៏ត្រូវពាក់អាវដៃវែង ខោជើងវែង មួកសុវត្ថិភាព ស្បែកជើងកវែងសុវត្ថិភាព និងស្រោមដៃដែលធន់នឹងការងារធ្ងន់ ដូចជាស្រោមដៃធ្វើពីស្បែកជាដើម។
ក៏ត្រូវប្រើឧបករណ៍ការពារឆ្អឹងស្មងជើង នៅក្នុងតំបន់គ្រោះថ្នាក់ជាពិសេសផងដែរ។

⑤ ការរៀបចំការងារ

មុនពេលចាប់ផ្តើមការងារ សូមពិនិត្យមើលរបៀបប្រើកុងតាក់ពន្លត់ម៉ាស៊ីន និងឧបករណ៍ផ្តាច់ចេញពីម៉ាស៊ីនពេលមានអាសន្ន។
មានសំឡេងរំខានខ្លាំងណាស់ នៅពេលធ្វើការជាមួយម៉ាស៊ីនកាត់ស្មៅហើយមិនអាចចូលទៅជិតអ្នកបញ្ជាម៉ាស៊ីនបានទេ។ ដូច្នេះហើយត្រូវសម្រេចអំពីរបៀបផ្តល់សញ្ញា (ដូចជា គ្រវីដៃទាំងពីរ ដើម្បីផ្តល់សញ្ញាដល់អ្នកបញ្ជាឱ្យពន្លត់ម៉ាស៊ីន)។
យកវត្ថុដែលធ្លាក់ចេញ ដូចជា ថ្ម មែកឈើ លួស និងកំប៉ុងទទេនៅជុំវិញកន្លែងដែលម៉ាស៊ីនកាត់ស្មៅនឹងត្រូវបានប្រើមុនពេលចាប់ផ្តើមការងារ។



យកកំប៉ុងទទេ ឬមែកឈើដែលនឹងហើរឡើងលើអាកាសចេញ មុនពេលចាប់ផ្តើមការងារ។

⑥ ក្នុងអំឡុងពេលធ្វើការងារ

អនុវត្តតាមនីតិវិធីការងារដែលបានសម្រេចជាមុន ហើយស្ថិតនៅក្នុងតំបន់កាត់ដែលអ្នកទទួលខុសត្រូវ។
សូមប្រយ័ត្ននឹងការផ្ទាត់ថយក្រោយ នៅពេលដែលផ្លែកាត់វិលក្នុងម៉ាស៊ីនកាត់ស្មៅប៉ះនឹងឧបសគ្គ ព្រោះវាអាចធ្វើឱ្យម៉ាស៊ីនកាត់ស្មៅបង្វិលភ្លាមឆ្ពោះទៅរកអ្នកបញ្ជា។
ការធ្វើការនៅលើជម្រាលគឺមានគ្រោះថ្នាក់ជាពិសេស។ រៀបចំជណ្តើរកាំខ្លី (ដោយប្រើកំណាត់ឈើនិងក្រចាប់រឹតធំមាំសម្រាប់រន្ធ) ហើយនៅពេលកំពុងធ្វើការទាំងកាំខាងលើ និងកាំខាងក្រោមក្នុងពេលដំណាលគ្នា អ្នកបញ្ជាម៉ាស៊ីនដែលត្រូវបានចាត់តាំង គួរប្តូរទីតាំងពីខាងមុខទៅខាងក្រោយវិញ។ លើសពីនេះទៀត នៅពេលដែលអ្នកបញ្ជាម៉ាស៊ីនជាច្រើនកំពុងធ្វើការជាមួយគ្នា សូមប្រាកដថាពួកគេមានគម្លាតពីគ្នាចម្ងាយចាប់ពី 15 ម៉ែត្រឡើងទៅ សូម្បីតែនៅលើផ្ទៃរាបស្មើក៏ដោយ។






## ការធានាសុវត្ថិភាពសម្រាប់គោយន្តភ្ជួររដី

① ការជ្រើសរើសគោយន្តភ្ជួររដី
ជ្រើសរើសគោយន្តភ្ជួររដីដែលមានវិញ្ញាបនបត្រត្រួតពិនិត្យសុវត្ថិភាព

② ការពិនិត្យនិងថែទាំ
ត្រួតពិនិត្យគោយន្តភ្ជួររដីដើម្បីមើលកម្រិតប្រេងរំអិល ពិនិត្យមើលថាតើខ្សែក្រវាត់ធូរឬខូចដែរឬទេ តើផ្លែរាស់ធូរឬខូចដែរឬទេ ពិនិត្យមើលគម្របសុវត្ថិភាព និងពិនិត្យមើលថាតើអំប្រាយ៉ាស និងហ្វ្រាំងមានដំណើរការដែរឬទេ ដោយផ្អែកតាមសៀវភៅណែនាំ។ ការត្រួតពិនិត្យនេះ គួរតែធ្វើជាប្រចាំ និងមុនពេលចាប់ផ្តើមការងារ។
ប្រសិនបើអ្នកបានបាត់បង់សៀវភៅណែនាំ សូមយកច្បាប់ចម្លងពីគេហទំព័ររបស់ផលិតករ ឬហាងលក់ឧបករណ៍កសិកម្ម។



ត្រួតពិនិត្យ និងថែទាំដោយផ្អែកតាមសៀវភៅណែនាំ។
(សម្រាប់ម៉ូដែលណាមួយ)

③ ការរៀបចំការងារ
មុនពេលចាប់ផ្តើមការងារ សូមពិនិត្យមើលកុងតាក់ពន្លត់ម៉ាស៊ីន និងរបៀបប្រើប្រាស់ឧបករណ៍សុវត្ថិភាពខាងក្រោម (ចូរចំណាំថា ឧបករណ៍អាចខុសគ្នាតាមម៉ូដែលរបស់វា)។

○ឧបករណ៍ការពារការកៀបជាប់ (ដងអំប្រាយ៉ាសសង្គ្រោះបន្ទាន់)
គឺជាឧបករណ៍ដែលត្រូវបានដំឡើងតាមរបៀបដែលអំប្រាយ៉ាសមេនឹងផ្តាច់ដោយស្វ័យប្រវត្តិនៅពេលផ្លាស់ទីថយក្រោយ ហើយអ្នកបញ្ជាត្រូវកៀបជាប់នៅចន្លោះឧបសគ្គ និងគោយន្តភ្ជួររដី
○អំប្រាយ៉ាសស្វ័យប្រវត្តិ (Dead man's clutch)
គឺជាអំប្រាយ៉ាសដែលត្រូវបានបង្កើតឡើង ដើម្បីផ្តាច់អំប្រាយ៉ាសកុំឱ្យបញ្ជូលលេខគោយន្ត នៅពេលដែលអ្នកបញ្ជាដកដៃរបស់ខ្លួនចេញពីអំប្រាយ៉ាសនោះ (សម្រាប់ប្រភេទអំប្រាយ៉ាសទូទៅ អ្នកបញ្ជាទាញអំប្រាយ៉ាសដើម្បីផ្តាច់ចរន្តអគ្គិសនីដែលកំពុងបញ្ចូលលេខគោយន្ត)។
○ហ្វ្រាំងដៃ
គឺជាហ្វ្រាំងការពារកុំឱ្យគោយន្តធ្វើចលនាដោយខ្លួនវាពេលនៅលើជម្រាល ឬផ្ទៃប្រហាក់ប្រហែលនេះ។

④ ក្នុងអំឡុងពេលធ្វើការងារ
ប្រភេទនៃគ្រោះថ្នាក់ដល់ជីវិតជាទូទៅបំផុត គឺនៅពេលដែលអ្នកបញ្ជាកំពុងថយក្រោយ ហើយបានកៀបជាប់ដោយចៃដន្យចន្លោះជញ្ជាំង ឬដើមឈើបញ្ឈរនៅពីក្រោយ ហើយគោយន្តនៅពីមុខពួកគេ។
○នៅពេលផ្លាស់ទីថយក្រោយ អ្នកបញ្ជាត្រូវតែប្រើល្បឿនទាប ហើយត្រៀមខ្លួនដើម្បីផ្តាច់អំប្រាយ៉ាសឱ្យលឿន។
○កុំបញ្ជាគោយន្តថយក្រោយនៅកន្លែងតូចចង្អៀតពីដំបូង។


ឧបទ្ទវហេតុដែលអ្នកបញ្ជាត្រូវបានកៀបជាប់នឹងដើមឈើខណៈពេលដែលផ្លាស់ទីថយក្រោយ

ឧបទ្ទវហេតុជាច្រើនពាក់ព័ន្ធនឹងអ្នកបញ្ជាដែលត្រូវបានទាញចូលទៅក្នុង ផ្នែកដែលវិល។
- ○ពន្លត់ម៉ាស៊ីនជានិច្ចនៅពេលដោះចំបើងឬស្មៅដែលជាប់នៅក្នុងម៉ាស៊ីន ដែលវិល។
- ○ផ្តាច់អំប្រាយ៉ាសវិល ពេលផ្លាស់ទីថយក្រោយ បត់ និងផ្លាស់ទីដោយមិនភ្ជួរ។
- ○បំពាក់គម្របខ្សែក្រវាត់ V ជានិច្ច។



ពន្លត់ម៉ាស៊ីនពេលដកចំបើង ឬស្មៅចេញ។

មនុស្សម្នាក់អាចរងរបួសដោយសារម៉ាស៊ីនធ្លាក់ ឬក្រឡាប់ផងដែរ។
- ○បត់គោយន្តក្នុងល្បឿនទាប ហើយប្រាកដថា មានកន្លែងគ្រប់គ្រាន់ សម្រាប់ការបត់។
- ○ចូល និងចេញពីដីជាំដុះ ឬឆ្លងកាត់ភ្លឺស្រែត្រង់មុមកែង។ ប្រើបន្ទះឈើទ្រជើងប្រសិនបើចាំបាច់។
- ○កុំចូលទៅជិតគែមផ្លូវដែលមានរុក្ខជាតិតូចៗដុះ។


គ្រោះថ្នាក់ធ្លាក់លើដី (ពេលឆ្លងភ្លឺស្រែ)

## ការធានាសុវត្ថិភាពសម្រាប់យានយន្តកសិកម្មដែលមានមនុស្សជិះ (ត្រាក់ទ័រ និងរថយន្តដឹកជញ្ជូនកសិកម្ម)

① ការជ្រើសរើសត្រាក់ទ័រដែលមានមនុស្សជិះ

ត្រាក់ទ័រដែលមានមនុស្សជិះស្ទើរតែទាំងអស់ដែលលក់ក្នុងប្រទេសជប៉ុន គឺជាម៉ូដែលដែលបានឆ្លងផុតលក្ខខណ្ឌតម្រូវនៃវិញ្ញាបនបត្រត្រួតពិនិត្យសុវត្ថិភាព។ ទោះជាយ៉ាងណាក៏ដោយ គ្រោះថ្នាក់ដល់ជីវិតដ៏ច្រើនសន្ធឹកសន្ធាប់នៅតែកើតឡើងជារៀងរាល់ឆ្នាំជាមួយនឹងម៉ូដែលទាំងនេះ។

ជាការល្អ អ្នកមិនត្រូវប្រើម៉ូដែលដែលចាស់ខ្លាំងនោះទេ ព្រោះវាមិនមានកាប៊ីនសុវត្ថិភាព (ដំបូល និងកញ្ចក់ជុំវិញកៅអីអង្គុយ) ឬស៊ុមសុវត្ថិភាព (រចនាសម្ព័ន្ធដែកនៅខាងក្រោយកៅអីអង្គុយ) ហើយមានគ្រោះថ្នាក់ណាស់។

② ការពិនិត្យនិងថែទាំ

អ្នកត្រូវតែត្រួតពិនិត្យ និងអនុវត្តការត្រួតពិនិត្យឱ្យបានទៀងទាត់មុនពេលចាប់ផ្តើមការងារ សម្រាប់គ្រឿងដូចខាងក្រោម តាមសៀវភៅណែនាំសម្រាប់ម៉ូដែលនីមួយៗ។
- ○សម្ពាធកង់ ការខូចខាតសំបកកង់ និងខ្ចៅរលុង កម្រិតប្រេងរំអិល និងទឹកស្អំម៉ាស៊ីន ខ្សែពានកង្ហាររលុង ខ្សែហ្វ្រាំងឆ្វេងនិងស្តាំ និងការដំណើរការរបស់វា គម្រប និងគម្របចង្កឹះ PTO កុងទ័រ ភ្លើង កញ្ចក់ និងសំឡេងម៉ាស៊ីន។

③ ការរៀបចំការងារ

ត្រូវតែពិនិត្យចំណុចដូចខាងក្រោម មុនពេលចាប់ផ្តើមការងារ។
- ○តើបុគ្គលិកមានទំនួលខុសត្រូវអ្វីខ្លះ ក្រៅពីក្រៅពីធ្វើជាអ្នកបញ្ជាត្រាក់ទ័រនៅថ្ងៃធ្វើការ? (ជាពិសេស ក្រៅពីអ្នកបញ្ជាត្រាក់ទ័រ តើបុគ្គលិកណាម្នាក់នឹងត្រូវធ្វើការងារនៅជិតត្រាក់ទ័រក្នុងអំឡុងពេលធ្វើការដែរឬទេ?)
- ○តើស្ថានភាពនៃទីកន្លែងដែលអ្នកបញ្ជាត្រាក់ទ័រ និងការងារដែលត្រូវបានធ្វើនៅថ្ងៃនោះមានលក្ខណៈដូចម្តេច? (តើមានកន្លែងណាមួយដែលមានគ្រោះថ្នាក់ដែរឬទេ ដូចជាមើលឃើញមិនសូវច្បាស់ ដីចំណោត ភ្លឺស្រែ និងផ្លូវទឹក?)
- ○ដំឡើងឧបករណ៍ចំណាំងផ្លាតធំៗនៅពេលបំពេញការងារយប់។
- ○យកទូរសព្ទទៅជាមួយ ដើម្បីទាក់ទងទៅអ្នកផ្សេងពេលមានអាសន្ន។
- ○ពាក់មួកសុវត្ថិភាព និងពាក់ខ្សែក្រវាត់ ។ល។

④ ក្នុងអំឡុងពេលធ្វើការងារ

សូមប្រយ័ត្នប្រយែងនូវចំណុចខាងក្រោមក្នុងពេលបំពេញការងារ ហើយព្យាយាមបើកបរដោយសុវត្ថិភាព។

○ពាក់មួកសុវត្ថិភាព និងប្រើខ្សែក្រវាត់សុវត្ថិភាព។

○នៅពេលបត់ សូមបើកបរយឺតៗ ហើយត្រូវប្រាកដថា មានផ្លាគ្រប់គ្រាន់សម្រាប់បត់។

○ចូល និងចេញពីដីដាំដុះ ឬឆ្លងកាត់ភ្លឺស្រែត្រង់មុំកែងយឺតៗ ។ ប្រើបន្ទះឈើទ្រដើងប្រសិនបើចាំបាច់។

○ភ្ជាប់ហ្វ្រាំងឆ្វេងនិងហ្វ្រាំងស្តាំជានិច្ច ពេលបើកបរលើផ្លូវ។

○កុំចូលទៅជិតគែមផ្លូវដែលមានរុក្ខជាតិតូចៗដុះ។



ការបត់ក្នុងល្បឿនលឿនភ្លាមៗ
ត្រូវបានហាមឃាត់ជាដាច់ខាត។



ប្រើប្រាស់ជម្រាបទាបដើម្បីចូល និងចាកចេញពីដីដាំដុះ



សូមប្រយ័ត្នពេលបើកបរលើគែមផ្លូវ
ដែលងាយក្រឡាប់។

○ពន្លត់ម៉ាស៊ីនជានិច្ចនៅពេលដោះចេញនូវវត្ថុចម្លែកដែលជាប់នៅក្នុងម៉ាស៊ីនកំពុងវិល។

○ហាមមិនឱ្យមនុស្សពីរនាក់ជិះលើត្រាក់ទ័រដែលមានមនុស្សជិះដោយគ្មានកៅអីជំនួយ ឬកៅអីសម្រាប់មនុស្សម្នាក់ជិះខាងក្រោយយានយន្តដឹកជញ្ជូនកសិកម្មនោះទេ។



កុំជិះជាមួយគ្នា។

◆សូមប្រុងប្រយ័ត្នចំពោះចំណុចដូចខាងក្រោមព្រោះគ្រោះថ្នាក់ក៏មានកើតឡើងលើផ្លូវសាធារណៈដែរ។

○ត្រូវមានបណ្ណបើកបរ ដើម្បីបើកបរលើផ្លូវសាធារណៈ។

○ត្រូវដឹងពីល្បឿនខុសគ្នាខ្លាំងជាមួយយានយន្តផ្សេង ជាពិសេសពេលបត់ស្តាំ។

○ជៀសវាងការបើកបរលើផ្លូវដែលមានចរាចរណ៍ច្រើន។

# 5 ការធានាសុវត្ថិភាពសម្រាប់ឧបករណ៍កសិកម្ម ជណ្តើរជើងបួន និងជណ្តើរជើងពីរ

① ឧបករណ៍កសិកម្ម (ចប ប៉ែល ដែកឬឈើឆាយ កាំបិត កណ្តៀវ និង កន្ត្រៃ ។ល។)

- គ្របមុខផ្លែឧបករណ៍កសិកម្ម ពេលមិនប្រើវា។
- រក្សាទុកឧបករណ៍កសិកម្មនៅក្នុងទីតាំងកំណត់ ដែលអាចមើលឃើញយ៉ាងងាយស្រួល។
- ពិនិត្យឧបករណ៍កសិកម្មក្រែងមានផ្លែរលុង ដើម្បីកុំឱ្យផ្លែកាត់របូតចេញពីដង។
- បន្ទាប់ពីប្រើឧបករណ៍កសិកម្មរួច សូមដក និងសម្អាតភាពកខ្វក់ និងវត្ថុដែលជាប់នឹងឧបករណ៍ចេញ ដើម្បីត្រៀមសម្រាប់ការប្រើប្រាស់នៅពេលក្រោយ។
- ពេលប្រើឧបករណ៍កសិកម្ម សូមប្រយ័ត្នចំពោះទីតាំងដែលអ្នកកំពុងធ្វើការ ដើម្បីកុំឱ្យប៉ះជាមួយមនុស្សជុំវិញអ្នក។



កុំប្រើចបកាប់ជិតៗប្រអប់ជើងរបស់អ្នក។

② ជណ្តើរជើងបួន និងជណ្តើរជើងពីរ

- ប្រើនៅទីតាំងដែលមានលំនឹង។
  * ដើម្បីដំឡើងជណ្តើរជើងបួន និងជណ្តើរជើងពីរក្នុងលក្ខណៈឱ្យមានលំនឹង សូមពិនិត្យមើលផ្លាទីតាំងដែលត្រូវដំឡើង ភាពរឹងរបស់ដី និងជម្រាលដី។ ដីអាចទន់ និងមិនស្មើគ្នានៅក្នុងចំការដំណាំ ដូច្នេះត្រូវប្រើសម្ភារៈទ្រាប់ និងបន្ទះឈើ ប្រសិនបើកន្លែងដែលអាចដំឡើងជណ្តើរជើងបួនបានមិនសូវមានសុវត្ថិភាពគួរឱ្យទុកចិត្តបាន។
  ប្រសិនបើកន្លែងដំឡើងជណ្តើរជើងបួនមិនមានលំនឹង សូមឱ្យបុគ្គលិកម្នាក់ទៀតកាន់ និងទប់ជណ្តើរ។




③ ដី

- រក្សាទុកដីឱ្យបានល្អ កុំឱ្យវាបំពុលទឹកក្រោមដី។
- សូមប្រយ័ត្នចំពោះកម្តៅដែលកើតឡើងនៅពេលបន្ថែមទឹកទៅក្នុងកំបោរ។
  * កំបោរ (CaO កាល់ស្យូមអុកស៊ីដ) មានប្រតិកម្មជាមួយទឹក ដើម្បីបង្កើតជាទឹកកំបោរ/កំបោរងាប់ ($Ca(OH)_2$ ឬកាល់ស្យូមអ៊ីដ្រុកស៊ីដ) ហើយសមាសធាតុនេះបង្កើតកម្តៅខ្លាំង និងបណ្តាលឱ្យមានកំណើនសីតុណ្ហភាព។



④ ចងច្រវាក់ ដើម្បីកុំឱ្យជណ្ដើរជើងបួនកន្ត្រៃកធំពេក។

* មុនពេលចាប់ផ្ដើមការងារ សូមពិនិត្យមើលថាបានចងភ្ជាប់ច្រវាក់ ដើម្បីការពារកុំឱ្យជណ្ដើរជើងបួនកន្ត្រៃកធំពេក។
ពេលប្រោះជណ្ដើរជើងពីរ ត្រូវប្រាកដថា ចុងនិងជើងជណ្ដើរស្ថិតក្នុងទីតាំង ឬស្ថានភាពដែលមិនរអិល។



⑤ នៅពេលដំឡើងជណ្ដើរជើងបួន ត្រូវឡើងទៅកាន់កាំទីមួយ ហើយពិនិត្យមើលលំនឹងរបស់វា។

* ដំបូង ត្រូវឈានជើងជាន់ទីមួយ ហើយពិនិត្យមើលថាវាមានលំនឹង និងមិនរង្គើ។
ពេលពិនិត្យមើលបែបនេះ ចូរកុំឡើងឱ្យផុតកាំទីមួយ។
មុនពេលឡើងជណ្ដើរជើងបួន ត្រូវពិនិត្យមើលថា មិនមានរបស់របរដែលមានគ្រោះថ្នាក់ស្ថិតនៅជុំវិញជណ្ដើរឡើយ។

⑥ កុំឈរនៅលើកាំកំពូលនៃជណ្ដើរ។



* កុំឈរនៅលើកាំកំពូលជណ្ដើរដើម្បីធ្វើការងារ ឬមិនត្រូវធ្វើការងារពេលផុតជំហរនៅលើជណ្ដើរឡើយ។ វានឹងបណ្ដាលឱ្យជណ្ដើរក្លាយជាមិនមានលំនឹង និងអាចបណ្ដាលឱ្យអ្នកធ្លាក់ ឬបណ្ដាលឱ្យជណ្ដើររលំ។

⑦ កុំកាន់របស់ធ្ងន់ ពេលឡើងនិងចុះជណ្ដើរ។

* ត្រូវអនុវត្តការងារនៅលើជណ្ដើរក្នុងបន្ទុកអតិបរមាដែលជណ្ដើរអាចទ្រមនុស្ស និងរបស់របរបាន។
កុំយករបស់ធ្ងន់ៗ ដូចជាប្រអប់ដែលមានផ្លែឈើពេញជាដើម នៅពេលឡើង ឬចុះជណ្ដើរ។



# 6 ការគ្រប់គ្រងសុខភាពនិងសុវត្ថិភាពនៅក្នុងក្រោលគោ-ក្របី

① ការងារសម្អាត
- ត្រូវសម្អាតផ្លូវគោក្របីឆ្លងកាត់ ឃ្លាំងដាក់ចំណី កន្លែងផឹកទឹក និងស្នូកទឹកជានិច្ច។
- រក្សាស្បែកជើងកវែង និងសម្លៀកបំពាក់ធ្វើការឱ្យស្អាត។



② ការងារកម្ចាត់មេរោគ
- នៅពេលចូលទៅក្នុងក្រោលគោ-ក្របី ត្រូវសម្លាប់មេរោគស្បែកជើងកវែងដោយដាក់ជើងចូលទៅក្នុងផើងទឹក។
- សម្រាប់យានយន្តដែលចូល និងចេញពីកសិដ្ឋាន ត្រូវសម្លាប់មេរោគលើសំបកកង់ដោយប្រើម៉ាស៊ីនបាញ់ថ្នាំសម្លាប់មេរោគ និងកម្រាលសម្រាប់សម្លាប់មេរោគសម្រាប់យានយន្ត។
- បាញ់ទឹកកំបោរជុំវិញក្រោលគោ-ក្របី ដើម្បីការពារកុំឱ្យមេរោគចូល។

③ ថែរក្សាបរិស្ថានសម្រាប់សត្វពូជ។
- រក្សាសីតុណ្ហភាពឱ្យបានត្រឹមត្រូវនៅក្នុងក្រោលគោ-ក្របី ដោយការបិទបាំងចន្លោះដែលខ្យល់ចូលក្នុងរដូវរងា និងដោយការសម្រួលដល់លំហូរខ្យល់ ដោយប្រើកង្ហារអគ្គិសនី និងកង្ហារខ្យល់ក្នុងរដូវក្តៅ។
- ត្រូវប្រាកដថា កម្រាលឥដ្ឋក្នុងក្រោលគោ-ក្របី ស្ងួតហើយស្អាត។
- សម្អាតរបស់របរផ្សេងៗ ដូចជាស្នូកទឹក និងធានាថាសត្វមានទឹកថ្មីផឹកជានិច្ច។

④ ថែទាំសត្វពូជក្នុងក្រោលដោយយកចិត្តទុកដាក់។
- កុំបង្កភាពតានតឹងដល់សត្វពូជ ដើម្បីឱ្យវាសម្រាកនិងស្រួលខ្លួន។
- ការបង្កាត់ពូជសត្វអាចកើតមានភ្លាមៗ ដូច្នេះ ត្រូវផ្តោតអារម្មណ៍នៅពេលធ្វើការនៅជុំវិញសត្វទាំងនេះជានិច្ច។



# 7 ការគ្រប់គ្រងសុវត្ថិភាពថ្នាំសម្លាប់សត្វល្អិត

① ការរក្សាទុក និងដឹកជញ្ជូនថ្នាំសម្លាប់សត្វល្អិត

- ត្រូវមានការប្រុងប្រយ័ត្នខ្ពស់នៅពេលរក្សាទុក និងដឹកជញ្ជូនថ្នាំសម្លាប់សត្វល្អិតមុនពេលប្រើប្រាស់ បន្ថែមពីលើការពង្រាវ និងបាញ់ថ្នាំសម្លាប់សត្វល្អិតនៅពេលប្រើប្រាស់វា។

  * ក្នុងវិស័យកសិកម្មបសុសត្វ ត្រូវគ្រប់គ្រងថ្នាំសំលាប់មេរោគតាមរបៀបដូចគ្នានឹងថ្នាំសម្លាប់សត្វល្អិតដែរ។

② ស្លៀកសម្លៀកបំពាក់ និងឧបករណ៍ការពារសមរម្យ។

- ដើម្បីធានាថា ថ្នាំសម្លាប់សត្វល្អិតមិនធ្លាក់ប៉ះស្បែករបស់បុគ្គលិក ត្រូវស្លៀកសម្លៀកបំពាក់ការពារការងារ ពាក់ម៉ាស់ ស្រោមដៃ និងវ៉ែនតាការពារដែលបានកំណត់។

  * កុំប្រើកន្សែងដៃជំនួសឱ្យម៉ាស់ដែលបានកំណត់។




① ស្រោមដៃ

✓ ពាក់ស្រោមដៃខាងក្នុងដៃអាវ

× ពាក់ស្រោមដៃគ្របចុងដៃអាវ



② ស្បែកជើងកវែង

✓ ពាក់ស្បែកជើងខាងក្នុងខោ

× ពាក់ស្បែកជើងគ្របជើងខោ



③ ពិនិត្យការណែនាំ (ស្លាក) លើថ្នាំសម្លាប់សត្វល្អិត។

- ត្រូវអនុលោមតាមស្តង់ដាប្រើប្រាស់ដែលមានរាយនៅក្នុងសេចក្តីណែនាំអំពីថ្នាំសម្លាប់សត្វល្អិត (ដូចជារបៀបប្រើប្រាស់ និងបម្រុងប្រយ័ត្ននៅពេលប្រើថ្នាំសម្លាប់សត្វល្អិត)។

  ឧទាហរណ៍ ក្នុងអំឡុងពេល OJT (ក្នុងពេលហាត់ការងារ) ត្រូវបង្ហាញសិក្ខាកាម អំពីរបៀបអនុវត្តការងារ និងត្រូវប្រាកដថា ពួកគេយល់ពីរបៀបរំលាយថ្នាំសម្លាប់សត្វល្អិតនៅពេលប្រើប្រាស់វា។

| ប្រភេទនៃគំនូសតាង | គំនូសតាង និងបម្រុងប្រយ័ត្នជាមុនដែលបានបង្ហាញ (ឧទាហរណ៍) | |
|---|---|---|
| បម្រើបម្រាស់ដែលបានហាមប្រាមសម្រាប់អ្នកដែលមានស្បែកងាយប្រតិកម្ម (ប្រយ័ត្នកន្ទួលលើស្បែក) | カブレ កន្ទួលលើស្បែក | ការងារដែលអ្នកមានស្បែកងាយប្រតិកម្មមិនគួរធ្វើ។ កុំប៉ះដំណាំដែលប្រើសារធាតុគីមីនេះ។ |
| កុំបាញ់ថ្នាំលើសំបុកឃ្មុំ (ប្រយ័ត្នសត្វឃ្មុំ) | | កុំប្រើ ប្រសិនបើមានហានិភ័យនៃការបាញ់ថ្នាំគីមីនេះលើ ឬជុំវិញសំបុកឃ្មុំ។ |
| ហាមប្រើប្រាស់ក្នុងទីតាំង | | កុំប្រើនៅក្នុងផ្ទះកញ្ចក់ ឬកន្លែងដែលការថ្នាំបាញ់នឹងកកជាគំនរ។ |



ការណែនាំអំពីថ្នាំសម្លាប់សត្វល្អិត

ប្រភព៖ គេហទំព័រ ជីវិតនិងដំណាំជប៉ុន (Crop Life Japan) សមាគមការពារដំណាំជប៉ុន (Japan Crop Protection Association) "ព័ត៌មានសំណួរនិងចម្លើយអំពីថ្នាំសម្លាប់សត្វល្អិត - តើថ្នាំសម្លាប់សត្វល្អិតមានសុវត្ថិភាពដែរឬទេ?- (វិធានការសុវត្ថិភាព និងព័ត៌មានអំពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតសម្រាប់កសិករ)" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ)

https://www.jcpa.or.jp/qa/a 5 _18.html

# 8 វិធានការការពារការសន្លប់ដោយត្រូវកម្តៅខ្លាំង

ការសន្លប់ដោយត្រូវកម្តៅខ្លាំង (Heatstroke) គឺជាពាក្យទូទៅដែលត្រូវបានសំដៅលើវិបត្តិដែលកើតឡើងនៅពេលមានអតុល្យភាពទឹកនិងអំបិល (សូដ្យូម) នៅក្នុងខ្លួនមនុស្សក្នុងបរិយាកាសដែលមានសីតុណ្ហភាពនិងសំណើមខ្ពស់ ហើយរាងកាយមិនអាចគ្រប់គ្រងកម្តៅបាន។ ការសន្លប់ដោយត្រូវកម្តៅខ្លាំងពេកត្រូវបានចាត់ថ្នាក់ជាកម្រិតទី 1 ដល់កម្រិតទី 4 ដោយផ្អែកលើកម្រិតនៃភាពធ្ងន់ធ្ងរនៅក្នុងគោលការណ៍ណែនាំការធ្វើរោគវិនិច្ឆ័យការសន្លប់ដោយត្រូវកម្តៅខ្លាំង (Heatstroke Diagnosis Guideline) ឆ្នាំ 2024 ដែលបង្កើតឡើងដោយសមាគមវេជ្ជសាស្ត្រជំងឺស្រួចស្រាវរបស់ជប៉ុន (Japanese Association for Acute Medicine) ។

| ប្រភេទ | រោគសញ្ញា | ការព្យាបាល | ភាពធ្ងន់ធ្ងរ |
|---|---|---|---|
| កម្រិតទី 1 | វិលមុខ ដួលសន្លប់ (ស្រាលក្បាលពេលឈរ) ស្វាបនិងគ្មានអារម្មណ៍ងងុយគេង បែកញើសច្រើន ឈឺសាច់ដុំ រឹងសាច់ដុំ (រមួលក្រពើជើង) | អាចព្យាបាលនៅកន្លែងធ្វើការបាន។<br>សម្រាកនៅក្នុងបន្ទប់ត្រជាក់ឆ្ងាយពីកម្តៅព្រះអាទិត្យ ឬមានម៉ាស៊ីនត្រជាក់ (ភាពត្រជាក់អកម្ម) ហើយទទួលទានទឹកដើម្បីបំពេញជាតិទឹក និងអេឡិចត្រូលីតឡើងវិញ។ ប្រសិនបើមិនគ្រប់គ្រាន់ទេ សូមប្រើការស្អំ (ស្អំរាងកាយរបស់អ្នកទទួលរងផលប៉ះពាល់ត្រជាក់ ដោយប្រើវិធីមួយចំនួន)។ | ទាប |
| កម្រិតទី 2 | ឈឺក្បាល ក្អួតចង្អោរ អស់កម្លាំងខ្លាំង បាក់ទឹកចិត្ត ខ្វះការផ្តោតអារម្មណ៍ និងសមត្ថភាពក្នុងការសម្រេចចិត្ត | ទាមទារឱ្យមានការពិនិត្យសុខភាពនៅស្ថាប័នវេជ្ជសាស្ត្រ។<br>គ្រប់គ្រងផលិតផលល្បាយ (វត្ថុរាវសម្រាប់បញ្ចូលទៅក្នុងខ្លួនតាមសរសៃឈាម) ដែលត្រូវបានរក្សាទុកក្នុងទូទឹកកក ឬសម្រាកក្នុងបន្ទប់ត្រជាក់ឆ្ងាយពីកម្តៅព្រះអាទិត្យ ឬបន្ទប់ដែលមានម៉ាស៊ីនត្រជាក់។ ប្រសិនបើវិធានការណាមួយ ឬវិធានការទាំងពីរមិនគ្រប់គ្រាន់ សូមផឹកដើម្បីបំពេញជាតិទឹក និងអេឡិចត្រូលីតឡើងវិញហើយប្រើវិធីស្អំបន្ថយកម្តៅ។ | |
| កម្រិតទី 3 | រោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំង 3 ខាងក្រោម<br>• រោគសញ្ញានៃប្រព័ន្ធសរសៃប្រសាទកណ្តាល (សន្លប់ ប្រកាច់)<br>• ខ្សោយមុខងារតម្រងនោមនិងថ្លើម<br>• ការកកឈាម | តម្រូវឱ្យមានការដឹកជញ្ជូនសង្គ្រោះបន្ទាន់ទៅកាន់ស្ថាប័នវេជ្ជសាស្ត្រ។<br>បន្ទាប់ពីការព្យាបាលនៅក្នុងមន្ទីរពេទ្យ សូមពិចារណានិងប្រើការព្យាបាលពហុជំនាញរួមទាំងការស្អំបន្ថយកម្តៅផងដែរ។ | ខ្ពស់ |
| កម្រិតទី 4 | សីតុណ្ហភាពស្នូលរបស់រាងកាយ គឺ 40 ដឺក្រេ ឬខ្ពស់ជាងនេះ ហើយអ្នកដែលមានបញ្ហាមិនអាចប្រាស្រ័យទាក់ទងបានទេ។ | តម្រូវឱ្យមានការដឹកជញ្ជូនសង្គ្រោះបន្ទាន់ទៅកាន់ស្ថាប័នវេជ្ជសាស្ត្រ។<br>ផ្តល់ការព្យាបាលពហុជំនាញភ្លាមៗ រួមទាំងការស្អំបន្ថយកម្តៅផងដែរ។ | |

សម្រាប់គ្រប់ឧស្សាហកម្មទាំងអស់ ចំនួនការស្លាប់ ឬរបួសក្នុងចំណោមបុគ្គលិកដែលអវត្តមានពីការងាររយៈពេលចាប់ពី 4 ថ្ងៃ ឡើងទៅដោយសារការសន្លប់ដោយត្រូវកម្តៅខ្លាំងពេកនៅកន្លែងធ្វើការ មានចំនួន 1,106 នាក់ក្នុងឆ្នាំ 2023 (ក្នុងនោះ 31 នាក់បានស្លាប់) ។ ក្នុងចំណោមចំនួននេះ សម្រាប់វិស័យកសិកម្ម ការស្លាប់ ឬរបួសមានចំនួន 27 នាក់ (2.4% នៃចំនួនសរុប) ក្នុងនោះមនុស្ស 4 នាក់បានស្លាប់ (12.9% នៃចំនួនសរុប)។ ការងារក្នុងវិស័យកសិកម្ម ជារឿយៗត្រូវបានអនុវត្តនៅខាងក្រៅ ហើយការងារមួយចំនួនត្រូវបានអនុវត្តនៅក្នុង ផ្ទះកញ្ចក់ដែលមានសីតុណ្ហភាពនិងសំណើមខ្ពស់ ដូច្នេះបុគ្គលិកអាចងាយនឹងសន្លប់ដោយត្រូវកម្តៅខ្លាំងពេក ក្នុងខែនៃរដូវក្តៅ។

## តម្លៃ WBGT (សន្ទស្សន៍កម្ដៅ)

តម្លៃ WBGT ត្រូវបានប្រើជាសន្ទស្សន៍កម្ដៅពេលវាយតម្លៃសម្ពាធកម្ដៅដោយសារបរិយាកាសក្ដៅ។
តម្លៃ WBGT គឺជាសូចនាករដែលផ្ដោតលើការផ្លាស់ប្ដូរកម្ដៅរវាងរាងកាយមនុស្ស និងបរិយាកាសខាងក្រៅ (តុល្យភាពកម្ដៅ) ហើយរួមបញ្ចូលកត្តាចំនួនបីដែលមានឥទ្ធិពលខ្លាំងលើតុល្យភាពកម្ដៅរាងកាយ គឺ (1) សំណើម (2) បរិយាកាសកម្ដៅជុំវិញ ដូចជា អាំងតង់ស៊ីតេពន្លឺព្រះអាទិត្យ និងកម្ដៅកាំរស្មី និង (3) សីតុណ្ហភាព។
តម្លៃ WBGT កាន់តែខ្ពស់ វាកាន់តែងាយកើតមានការសន្លប់ដោយត្រូវកម្ដៅខ្លាំង។

តម្លៃ WBGT ត្រូវបានវាស់ស្ទង់ ដោយប្រើឧបករណ៍វាស់ WBGT ដែលបំពាក់ដោយឧបករណ៍ចាប់សញ្ញាអំពូលខ្មៅ (ស្របតាមស្តង់ដាឧស្សាហកម្មជប៉ុន JIS Z8504 ឬ JIS B 7922) ។
ប្រសិនបើមិនមានឧបករណ៍វាស់ស្ទង់នេះទេ តម្លៃ WBGT ដែលបានព្យាករណ៍ និងតម្លៃជាក់ស្ដែង អាចត្រូវបានពិនិត្យនៅលើគេហទំព័រព័ត៌មានអំពីការការពារការសន្លប់ដោយត្រូវកម្ដៅខ្លាំង (Heat Stroke Prevention Information) ដែលផ្ដល់ដោយក្រសួងបរិស្ថាន (https://www.wbgt.env.go.jp/wbgt_data.php) ។

## ការងារកសិកម្ម និងសន្ទស្សន៍កម្ដៅ

នៅកន្លែង (កន្លែងធ្វើការក្ដៅហើយសើម) ដែលតម្លៃ WBGT លើសពីតម្លៃស្តង់ដា (ឬមានហានិភ័យប្រឈមនឹងការកើតមានបញ្ហានេះ) អាចនឹងមានលទ្ធភាពខ្ពស់ធ្វើឱ្យបុគ្គលិកកើតមានការសន្លប់ដោយត្រូវកម្ដៅខ្លាំង។ ដូច្នេះជាដំបូង ចាំបាច់ត្រូវខិតខំវាស់ស្ទង់តម្លៃ WBGT ខណៈពេលដែលមនុស្សកំពុងធ្វើការ។
តម្លៃ WBGT ដែលវាស់ស្ទង់ ត្រូវបានប្រៀបធៀបទៅនឹងតម្លៃ WBGT ស្តង់ដានៅក្នុងតារាងខាងក្រោម ហើយត្រូវមានវិធានការបន្តបន្ទាប់នៅកន្លែងធ្វើការក្ដៅនិងសើម។

① មានបំណងកាត់បន្ថយតម្លៃ WBGT ដោយប្រើដូចជា "ដំបូលសាមញ្ញដែលអាចទប់ស្កាត់ពន្លឺព្រះអាទិត្យដោយផ្ទាល់ និងផ្លាតកម្ដៅ" និង "ឧបករណ៍ខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់"។
② រៀបចំកន្លែងសម្រាកត្រជាក់ដែលបំពាក់ដោយម៉ាស៊ីនត្រជាក់ ឬកន្លែងសម្រាកត្រជាក់នៅក្នុងម្លប់ក្បែរកន្លែងធ្វើការក្ដៅហើយសើម។
③ ខិតខំប្រឹងប្រែងរៀបចំរបស់របរនិងសម្ភារៈផ្សេងៗ ដូចជាទឹកកក ក្រណាត់ត្រជាក់ស្អំមុខ ងូតទឹកត្រជាក់ និងងូតទឹកផ្កាឈូក ដែលបុគ្គលិកអាចប្រើបានដើម្បីធ្វើឱ្យរាងកាយរបស់ពួកគេត្រជាក់សមស្របនៅកន្លែងធ្វើការក្ដៅហើយសើម និងនៅជិតកន្លែងបែបនេះ។
④ ផ្ដល់ទឹកបរិភោគនៅកន្លែងធ្វើការក្ដៅហើយសើម ដើម្បីឱ្យបុគ្គលិកអាចបំពេញជាតិទឹក និងអំបិលបានទៀងទាត់ និងដោយងាយស្រួល។

| អាំងតង់ស៊ីតេការងាររូបវន្ត | ឧទាហរណ៍ការងារ | សន្ទស្សន៍កម្ដៅ (WBGT) តម្លៃយោង |
| --- | --- | --- |
| ការសម្រាក | ការសម្រាក | 33<br>(32 សម្រាប់មនុស្សដែលមិនស៊ាំនឹងកម្ដៅ) |
| ការងារស្រាល | • ការងារដោយដៃស្រាលៗក្នុងស្ថានភាពអង្គុយ ឬឈរស្រួល (ដូចជាការសរសេរ ការចុះបញ្ជីគណនេយ្យ ជាដើម)<br>• ការងារដោយប្រើដៃ (ការពិនិត្យ ផ្គុំ ឬបែងចែកសម្ភារៈស្រាលៗ)<br>• ការងារដោយប្រើដៃ និងជើង (ការបើកបរយានយន្តក្នុងលក្ខខណ្ឌធម្មតា ការបញ្ជាកុងតាក់ និងឈ្នាន់ជើង) | 30<br>(29 សម្រាប់មនុស្សដែលមិនស៊ាំនឹងកម្ដៅ) |
| ការងារកម្រិតមធ្យម | • ការបញ្ជាត្រាក់ទ័រ យានយន្តធុនធ្ងន់ ការកាត់រុក្ខជាតិតូចៗ ការបេះផ្លែឈើនិងបន្លែ<br>• ការរុញនិងអូសរទេះទម្ងន់ស្រាល និងរទេះកង់មុខ | 28<br>(26 សម្រាប់មនុស្សដែលមិនស៊ាំនឹងកម្ដៅ) |
| ការងារដែលទាក់ទងនឹងការប្រើកម្លាំង | • ការប្រើប៉ែល ការកាត់ស្មៅ ការជីកនិងអារដោយដៃ<br>• ការរុញនិងអូសរទេះទម្ងន់ធ្ងន់ និងរទេះកង់មុខ | 25<br>(22 សម្រាប់មនុស្សដែលមិនស៊ាំនឹងកម្ដៅ) |
| ការងារដែលទាក់ទងនឹងការប្រើកម្លាំងខ្លាំង | • ការជីកដោយកម្លាំងខ្លាំងដោយប្រើប៉ែល ពូថៅយោល ការឡើងជណ្ដើរ និងការរត់ | 23<br>(18 សម្រាប់មនុស្សដែលមិនស៊ាំនឹងកម្ដៅ) |



ព័ត៌មាននេះត្រូវបានរៀបចំឡើងដោយផ្អែកលើឧបសម្ព័ន្ធ A "តម្លៃយោងសន្ទស្សន៍សម្ពាធកម្ដៅ WBGT" របស់ស្តង់ដាឧស្សាហកម្មជប៉ុន Z8504 (ការងារវិទ្យានៃបរិយាកាសកម្ដៅ -- ការវាយតម្លៃសម្ពាធកម្ដៅដោយប្រើសន្ទស្សន៍ WBGT (សីតុណ្ហភាពកម្ដៅសកល)) (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) ព្រមទាំង "ការជំរុញអនុវត្តឱ្យបានហ្មត់ចត់បន្ថែមទៀតនូវវិធានការការពារការសន្លប់ដោយត្រូវកម្ដៅខ្លាំងពេកក្នុងការងារកសិកម្ម" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) ដូចដែលបានរាយការណ៍ដោយការិយាល័យរបស់ប្រធាន ការិយាល័យសម្ភារៈផលិតកម្មកសិកម្ម ការិយាល័យផ្សព្វផ្សាយនិងបច្ចេកវិទ្យា ការិយាល័យផលិតកម្មដំណាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី 10 ខែកក្កដា ឆ្នាំ 2024 ។

ប្រសិនបើអ្នកសន្លប់ដោយត្រូវកម្ដៅខ្លាំង មិនអាចផឹកទឹកដោយខ្លួនឯងបានទេ ឬរោគសញ្ញារបស់ពួកគេមិនធូរស្រាល សូម្បីតែបន្ទាប់ពីការសង្គ្រោះបឋមក៏ដោយ ពួកគេគួរតែត្រូវបាននាំទៅស្ថាប័នវេជ្ជសាស្ត្រភ្លាមៗដើម្បីពិនិត្យសុខភាព។



# 9 វិធានការការពារការឈឺចង្កេះ

មានសារៈសំខាន់ណាស់ក្នុងការអនុវត្តការអប់រំឱ្យបានទូលំទូលាយ និងបន្តបន្ទាប់អំពីសុខភាពការងារ និងគ្រប់គ្រងកត្តាចំនួន 3 គឺការងារ បរិយាកាសការងារ និងសុខភាព ដើម្បីការពារការឈឺចង្កេះ ក្នុងការងារទាក់ទងនឹងវិស័យកសិកម្ម។

ជាពិសេស ខាងក្រោមនេះគឺជាវិធានការដ៏មានប្រសិទ្ធភាពក្នុងការគ្រប់គ្រងការងារ។

① ស្វ័យប្រវត្តិកម្ម ការសន្សំកម្លាំងពលកម្ម

គឺស្វ័យប្រវត្តិកម្មការងារដោយប្រើម៉ាស៊ីន នៅពេលធ្វើការងារពាក់ព័ន្ធនឹងការលើកដាក់របស់ធ្ងន់ៗដែលធ្វើឱ្យឈឺចង្កេះ និងការងារដែលឱ្យបុគ្គលិកធ្វើការក្នុងឥរិយាបថខុសពីធម្មជាតិ។ ប្រសិនបើបញ្ហានេះពិបាក សូមប្រើវិធានការសន្សំកម្លាំងពលកម្ម ដើម្បីកាត់បន្ថយបន្ទុករបស់បុគ្គលិកដោយប្រើឧបករណ៍ដូចជា រទេះរុញបាតរាប ឬឧបករណ៍ជំនួយ។

② ឥរិយាបថការងារ និងការធ្វើចលនា

បុគ្គលិកគួរតែដាក់រាងកាយរបស់ខ្លួនឱ្យជិតនឹងការងារដែលត្រូវធ្វើ តាមដែលអាចធ្វើទៅបាន។ ពេលដែលការងារតម្រូវឱ្យប្រើឥរិយាបថខុសពីធម្មជាតិ ត្រូវកាត់បន្ថយកម្រិតនៃឥរិយាបថនោះ (ដូចជា ឥរិយាបថឱនទៅមុខ និងបង្វិលខ្លួនជាដើម) ហើយកាត់បន្ថយភាពញឹកញាប់ និងរយៈពេលនៃឥរិយាបថនោះ។

លៃតម្រូវជើងម៉ានិងកៅអីធ្វើការងារឱ្យមានកម្ពស់សមស្រប។

ត្រូវប្រាកដថា កម្ពស់នៃជើងម៉ាឬកៅអីធ្វើការងារ គឺធ្វើយ៉ាងណាឱ្យមុំនៃកែងដៃរបស់បុគ្គលិកបត់ប្រហែល 90 ដឺក្រេ។



ការដឹកជញ្ជូនដោយប្រើរទេះរុញបាតរាប។

③ ប្រព័ន្ធអនុវត្តការងារ

នៅពេលកំណត់ម៉ោងការងារ និងបន្ទុកការងារ សូមពិចារណានូវកត្តាមួយចំនួនដូចជា ចំនួនមនុស្សដែលធ្វើការងារ ប្រភេទការងារ រយៈពេល ទម្ងន់ ស្វ័យប្រវត្តិកម្ម និងស្ថានភាពសន្សំកម្លាំងពលកម្ម ហើយមិនត្រូវអនុញ្ញាតឱ្យមនុស្សធ្វើការណាដែលនាំឱ្យឈឺចង្កេះនោះឡើយ។

④ ការបង្កើតស្តង់ដាការងារ

បង្កើតស្តង់ដាការងារ សម្រាប់ឥរិយាបថការងារ ចលនា នីតិវិធី និងរយៈពេលការងារ។ ស្តង់ដាការងារត្រូវតែត្រួតពិនិត្យជាប្រចាំដោយគិតគូរពីបុគ្គលិកលក្ខណៈ និងកម្រិតជំនាញរបស់បុគ្គលិក។ ដូចគ្នានេះដែរ ស្តង់ដាការងារត្រូវតែបានពិនិត្យឡើងវិញរាល់ពេលដែលគ្រឿងម៉ាស៊ីន ឬឧបករណ៍ថ្មីៗត្រូវបាននាំមកប្រើនៅកន្លែងធ្វើការ។



អង្គុយច្រហោងចុះ ហើយលើកដោយប្រើកម្លាំងជើងរបស់អ្នក។



កាន់បន្ទុកលើកផ្ទឹបនឹងខ្លួនរបស់អ្នក។

⑤ ការសម្រាក បន្ទុកការងារ និងការងាររួមបញ្ចូលគ្នា

ផ្តល់ការសម្រាកតាមដែលចាំបាច់ និងប្រាកដថា បុគ្គលិកផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនក្នុងអំឡុងពេលនេះ។

ពេលដែលការងារតម្រូវឱ្យប្រើឥរិយាបថខុសពីធម្មជាតិ ឬនៅពេលបំពេញការងារដដែលៗ ត្រូវរួមបញ្ចូលការងារនោះជាមួយភារកិច្ចផ្សេងទៀត ហើយជៀសវាងការងារបន្តគ្នានៅពេលណាដែលអាចធ្វើទៅបាន។



បង្កើតវិធីសាស្ត្រដើម្បីដោះស្រាយជាមួយរបស់របរដែលពិបាកយួរ។



ចែកជាបរិមាណតូចៗ ហើយយួរ។

# 10 វិធានការការពារការសត្វល្អិតខាំ-ទិច

## ឃ្មុំទិច

បុគ្គលិកកសិកម្មគួរប្រយ័ត្នសត្វឃ្មុំទិចនៅរដូវក្ដៅ។ ពេលរុក្ខជាតិនៅកន្លែងមានស្មៅមិនដែលបានចូលទៅដល់ក្នុងអំឡុងពេលការងារស្ដង់ដា បុគ្គលិកប្រហែលជាមិនបានចាប់អារម្មណ៍ថាមានសំបុកឃ្មុំ ហើយត្រូវឃ្មុំទិចនោះឡើយ។
ក្នុងចំណោមប្រភេទឃ្មុំដែលទិចមនុស្ស សត្វឃ្មុំដែលខ្លាចបំផុតនោះ គឺសត្វឪម៉ាល់ និងឪម៉ាល់ពណ៌ត្នោត (Paper wasps) ។ ជាពិសេស សត្វឪម៉ាល់ពណ៌លឿង (Yellow jackets) ដែលជាសត្វមានភាពកាចខ្លាំង។ ឃ្មុំផ្ដល់សញ្ញាទៅជាស្ថានភាពព្រមានជាមុន ហើយធ្វើការគំរាមកំហែង នៅពេលដែលមានអ្វីមួយចូលទៅជិតសំបុករបស់វា ហើយពួកវានឹងវាយប្រហារ ប្រសិនបើសំបុករបស់វាមានការរំខាន។
ចំនួនអ្នកស្លាប់ដោយសារឃ្មុំទិចនៅប្រទេសជប៉ុន មានចំនួន 21 នាក់ក្នុងឆ្នាំ 2023 ។

ចំនួនអ្នកស្លាប់ដោយសារឃ្មុំទិចនៅប្រទេសជប៉ុន (ឯកតា៖ នាក់)

| ប្រភេទ | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|
| ចំនួនអ្នកស្លាប់ដោយសារឃ្មុំទិច | 11 | 13 | 15 | 20 | 21 |

ប្រភព៖ ស្ថិតិសំខាន់ៗចេញដោយក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
នៅពេលសត្វឃ្មុំទិច វាអាចបង្កើតស្ថានភាពគ្រោះថ្នាក់ ដោយសារតែប្រតិកម្មខ្លាំង*។

* នេះសំដៅលើស្ថានភាពគំរាមកំហែងធ្ងន់ធ្ងរដល់អាយុជីវិត ដែលមនុស្សម្នាក់ទទួលរងនូវបញ្ហាការដកដង្ហើម និងសម្ពាធឈាមធ្លាក់ចុះក្នុងរយៈពេលដ៏ខ្លីបំផុត (ពីច្រើននាទីរហូតដល់ 30 នាទី) ដោយសារតែប្រតិកម្មទៅនឹងថ្នាំ ឬសារធាតុគីមីស្រដៀងគ្នា។




រោគសញ្ញានៃប្រតិកម្មខ្លាំង

| | ទាក់ទងនឹងប្រព័ន្ធរាងកាយទាំងមូល | ប្រព័ន្ធដង្ហើម | ប្រព័ន្ធឈាមរត់ | ប្រព័ន្ធរំលាយអាហារ | ប្រព័ន្ធសរសៃប្រសាទ | ស្បែក |
|---|---|---|---|---|---|---|
| អត្តនោម័តិរោគសញ្ញា | • អន្ទះសារ<br>• ទន់ខ្សោយ | • ពិបាកដកដង្ហើម<br>• តឹងបំពង់ក | • ញ័របេះដូង | • រកកល់ចង់ក្អួត<br>• ការឈឺចាប់ត្រង់ពោះ<br>• ចង់បន្ទោបង់<br>• ចង់បត់ជើងតូច | • វិលមុខ<br>• ស្ពឹក<br>• ដូងក្នុងត្រចៀក | • ហើមខ្លួនទាំងមូល<br>• រមាស់ |
| សត្យានុម័តរោគសញ្ញា | • ញើសត្រជាក់ | • កណ្ដាស់<br>• ការដកដង្ហើមតឹង<br>• ពិបាកដកដង្ហើម | • សម្ពាធឈាមថយចុះ<br>• ជីពចរខ្សោយ<br>• ជីពចរលោតញាប់ | • ក្អួត<br>• រាគរូស<br>• បន្ទោបង់លាមកឬទឹកមូត្រដោយមិនដឹងខ្លួន | • ការប្រកាច់<br>• វង្វេងស្មារតី | • ឡើងកន្ទាលត្រអាកពេញទាំងខ្លួន<br>• សម្បុរស្លាំងពេញដងខ្លួន |

ត្រូវធ្វើការព្យាបាលដូចខាងក្រោម ពេលមានសត្វឃ្មុំទិច។

① ចាកចេញពីកន្លែងដែលបុគ្គលិកត្រូវបានទិច ហើយដកពិសចេញភ្លាមៗដោយប្រើឧបករណ៍ស្រូបយកពិសសត្វឃ្មុំ។
② ប្រើទឹកត្រជាក់ដើម្បីស្អំកន្លែងដែលរងប៉ះពាល់ និងបន្ថយល្បឿនពិសដែលធ្វើដំណើរចូលក្នុងខ្លួន។
③ លាបប្រេងឬក្រមួនប្រឆាំងប្រតិកម្មក្នុងខ្លួន (anti-histamine ointment) នៅកន្លែងដែលសត្វឃ្មុំ ទិច។
អ្នកដែលទទួលបានវេជ្ជបញ្ជាប្រើថ្នាំគ្រាប់ប្រឆាំងប្រតិកម្មក្នុងខ្លួន (Anti-histamine tablets) គួរតែលេបថ្នាំ។
④ ប្រសិនបើមានរោគសញ្ញាដូចជា កន្ទួល ក្អក ឬវិលមុខ ត្រូវបញ្ជូនជនរងគ្រោះទៅស្ថាប័នវេជ្ជសាស្ត្រភ្លាមៗ។
⑤ នៅពេលបញ្ជូនជនរងគ្រោះ ត្រូវដឹកជនរងគ្រោះទៅកាន់រថយន្តសង្គ្រោះបន្ទាន់ដោយប្រើស្នែងសែង។ កុំឱ្យជនរងគ្រោះដើរដោយខ្លួនឯង ឬជិះលើខ្នងរបស់អ្នក។

## ការឆ្លងមេរោគដោយសារចៃ

ប្រសិនបើមនុស្សម្នាក់ត្រូវបានចៃខាំ ពួកគេអាចនឹងឆ្លងមេរោគគ្រុនក្តៅធ្ងន់ធ្ងរដោយជំងឺដែលមានប្លាកែត ថយចុះ (Severe Fever with Thrombocytopenia Syndrome - SFTS) ជំងឺរលាកខួរក្បាលដោយសារចៃខាំ គ្រុនក្តៅ Japanese Spotted Fever គ្រុនក្តៅដោយសារចៃខាំ (Scrub Typhus) ឬ ជំងឺ Lyme ។
លក្ខណៈរបស់ចៃ និងព័ត៌មានផ្សេងទៀតមានដូចខាងក្រោម។

① របាយសត្វចៃ
ចៃគឺខុសគ្នាពីពួកសត្វល្អិតដែលកាត់ខោអាវ [មេម៉ង់ផ្សិត (mold mite) និងខ្ទូត (house dust mites)] ដែល រស់នៅក្នុងផ្ទះ។ ចៃភាគច្រើនរស់នៅក្រៅផ្ទះក្នុងព្រៃ និងវាលស្មៅ។ ជួនកាលគេឃើញវានៅជុំវិញទីក្រុងនិងទីប្រជុំជន ហើយរាយប៉ាយពាសពេញប្រទេសជប៉ុន។ មានហានិភ័យចៃខាំពេលធ្វើការងារកសិកម្មនៅតាមវាលឬនៅពេលកាត់គុម្ពោតព្រៃ។

② អំឡុងពេលដែលចៃមានភាពសកម្ម
ចៃមានសកម្មភាពខ្លាំងចាប់ពីនិទាឃរដូវ (រដូវស្លឹកឈើលាស់) រហូតដល់សរទរដូវ (រដូវស្លឹកឈើជ្រុះ)។ ប៉ុន្តែនៅក្នុងតំបន់ដែលមានអាកាសធាតុក្តៅ ចៃនៅតែមានភាពសកម្មដដែល សូម្បីតែក្នុងរដូវរងា ទោះបីជាវាមិនសូវសកម្មនៅពេលនេះក៏ដោយ ដូច្នេះបុគ្គលិកត្រូវតែប្រុងប្រយ័ត្ន។

③ របៀបបង្ការ
ដើម្បីការពារការឆ្លងជំងឺពីសត្វចៃ មិនត្រូវឱ្យវាខាំនោះឡើយ។
ពេលធ្វើដំណើរទៅកន្លែងដែលមានសត្វចៃជាច្រើនរស់នៅ ដូចជាកន្លែងដែលមានស្មៅនិងភ្នំ ជៀសវាងការបញ្ចេញស្បែករបស់អ្នកនៅត្រង់ដៃ ជើង និងក តាមដែលអាចធ្វើទៅបាន ហើយក៏ត្រូវពាក់សម្លៀកបំពាក់ដែលមិនមានចន្លោះឱ្យចៃចូលខាំបានក្នុងពេលធ្វើការងារ។

<u>ប្រសិនបើចៃខាំ</u>
ចៃជាច្រើនប្រភេទ ខាំទម្លុះស្បែកដោយមាត់របស់វា ហើយបឺតឈាមក្នុងរយៈពេលយូរ (ក្នុងរយៈពេលជាច្រើនថ្ងៃ ហើយវាអាចមានរយៈពេលរហូតដល់ 10 ថ្ងៃ)។ មនុស្សដែលចៃខាំ ច្រើនតែមិនដឹងខ្លួន និងមិនបានកត់សម្គាល់ដឹងពីចៃនោះទេ ព្រោះមិនមានការឈឺចាប់បន្ទាប់ពីវាបានខាំឡើយ។
ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីខាំបាន 2 ទៅ 3 ថ្ងៃក្រោយមក ទំហំរបស់ចៃនឹងកើនឡើងនៅពេលដែលវាបឺតឈាម ហើយពួកគេអាចមានអារម្មណ៍រមាស់ មិនស្រួល ឬអារម្មណ៍ក្រហាយ និងឈឺចាប់តិចៗ។

<u>ប្រសិនបើអ្នកឃើញចៃនៅលើខ្លួនរបស់អ្នក</u>
ប្រសិនបើអ្នកឃើញចៃខាំហើយជាប់នឹងខ្លួនរបស់អ្នក រួចព្យាយាមទាញវាចេញពីស្បែករបស់អ្នកដោយបង្ខំ បំណែករបស់ចៃនឹងនៅតែស្ថិតក្រោមស្បែករបស់អ្នក ឬការញេចខ្លួនរបស់ចៃអាចនឹងបណ្តាលឱ្យមានមេរោគ ឬបាក់តេរីដែលមានក្នុងខ្លួនចៃ ចូលមកក្នុងខ្លួនអ្នក។ ដូច្នេះហើយ អ្នកត្រូវតែស្វែងរកការព្យាបាលនៅស្ថាប័នវេជ្ជសាស្ត្រ (គ្រូពេទ្យជំនាញខាងសើស្បែក ឬគ្លីនិកវះកាត់)។

<u>បន្ទាប់ពីចៃខាំរួច</u>
នៅពេលដែលអ្នកត្រូវបានចៃខាំ សូមតាមដានសុខភាពរបស់អ្នកក្នុងរយៈពេលប្រហែល 3 សប្តាហ៍ ដើម្បីមើលថាតើអ្នកមានរោគសញ្ញាដូចជាគ្រុនក្តៅ អស់កម្លាំង កន្ទួល ឈឺសន្លាក់ ឈឺពោះ និងរាគរូសដែរឬអត់។ ប្រសិនបើមានរោគសញ្ញាទាំងនេះកើតឡើង សូមប្រញាប់ស្វែងរកការព្យាបាលនៅស្ថាប័នវេជ្ជសាស្ត្រ ហើយជូនដំណឹងទៅវេជ្ជបណ្ឌិតថាអ្នកត្រូវបានចៃខាំ (នៅពេលណា កន្លែងណា និងផ្នែកណាមួយនៃរាងកាយរបស់អ្នក)។

ឯកសារយោង៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការិយាល័យផលិតកម្មដំណាំ នាយកការិយាល័យផ្សព្វផ្សាយ និងបច្ចេកវិទ្យា "ចំណុចសំខាន់ៗទាក់ទងនឹងចៃខាំក្នុងការងារកសិកម្ម" (ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) ចុះថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2013 - 24 ផលិតកម្មលេខ 2933 ។

# 11 វិធានការការពារកង្វះអុកស៊ីសែន

## ការកើតឡើងនៃកង្វះអុកស៊ីសែន និងគ្រោះថ្នាក់ផ្សេងទៀត

ជារៀងរាល់ឆ្នាំ គ្រោះថ្នាក់មួយចំនួនកើតឡើងទាក់ទងនឹងការពុលកង្វះអុកស៊ីសែន និងការពុលអ៊ីដ្រូសែនស៊ុលផួ (កង្វះអុកស៊ីសែន និងគ្រោះថ្នាក់ផ្សេងទៀត)។ ក៏មានការស្លាប់ដែលបណ្ដាលមកពីគ្រោះថ្នាក់មួយចំនួនទាំងនេះផងដែរ។
កង្វះអុកស៊ីសែន និងគ្រោះថ្នាក់ផ្សេងទៀតមានអត្រាស្លាប់ខ្ពស់ណាស់។ មូលហេតុមួយក្នុងចំណោមហេតុផលទាំងនេះ គឺដោយសារតែកង្វះការយល់ដឹងអំពីគ្រោះថ្នាក់ដោយសារកង្វះអុកស៊ីសែនក្នុងចំណោមក្រុមហ៊ុនអាជីវកម្ម និងបុគ្គលិក។ ទប់ស្កាត់ការកើតឡើងនៃគ្រោះថ្នាក់ទាំងនេះ ដោយចាត់វិធានការសមស្របក្នុងទម្រង់ជាការវាស់ស្ទង់បរិយាកាសការងារ ការបង្កើតខ្យល់ចេញចូលឱ្យបានត្រឹមត្រូវ និងការប្រើប្រាស់ឧបករណ៍ការពារផ្លូវដង្ហើម ដូចជាម៉ាស់ខ្យល់ ជាដើម។




ប្រភព៖ "ឧបទ្ទវហេតុនៃការរងរបួសឧស្សាហកម្មដោយសារតែកង្វះអុកស៊ីសែន និងការពុលអ៊ីដ្រូសែនស៊ុលផួ"
(ឯកសារជាភាសាជប៉ុនតែប៉ុណ្ណោះ) ពីគេហទំព័ររបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
(https://www.mhlw.go.jp/stf/newpage_05929.html)

## ទីតាំងដែលមានគ្រោះថ្នាក់ដូចជាកន្លែងដែលមានកង្វះអុកស៊ីសែន

កង្វះអុកស៊ីសែនសំដៅលើលក្ខខណ្ឌដែលកំហាប់អុកស៊ីសែននៅក្នុងខ្យល់មានចំនួនក្រោម 18% ឬកំហាប់អ៊ីដ្រូសែនស៊ុលផួក្នុងខ្យល់លើសពី 10 ភាគក្នុងមួយលានភាគ។ កន្លែងខាងក្រោមនេះ អាចចាត់ទុកថាជាទីតាំងគ្រោះថ្នាក់ដោយសារកង្វះអុកស៊ីសែនសម្រាប់ការងារដែលទាក់ទងនឹងវិស័យកសិកម្ម។

① នៅខាងក្នុងលូទឹក និងធុងផ្ទុកទឹកភ្លៀង ឬធុងដែលមានទឹកភ្លៀងកន្លងមក
(មានហានិភ័យពីកង្វះអុកស៊ីសែនដោយសារអុកស៊ីតកម្មជាតិដែកក្រោមដី និងអតិសុខុមប្រាណប្រើប្រាស់អុកស៊ីសែន)




កម្រិតអុកស៊ីសែនថយចុះដោយសារតែការដកដង្ហើមរបស់អតិសុខុមប្រាណដែលកើតឡើងថ្មីៗហើយរហ័ស។

② នៅខាងក្នុងធុងសម្ពាធ (Silos) បន្ទប់នៅក្នុងដីសម្រាប់ដាក់វត្ថុផ្សេងៗ (Cellars) ឃ្លាំង គម្របបើកចេញចូល (Hatches) ឬរណ្តៅដាក់គ្រាប់ធញ្ញជាតិ ឬចំណីសត្វ បន្លែនិងផ្លែឈើទុំ ដំណុះគ្រាប់ពូជឬការដាំដុះផ្សិត (អុកស៊ីសែនត្រូវបានប្រើប្រាស់ដោយការដកដង្ហើមរបស់គ្រាប់ធញ្ញជាតិ)




ការដកដង្ហើមរបស់ស្មៅនិងចំណីសត្វ

ម្យ៉ាងវិញទៀត នៅក្នុងវិស័យកសិកម្ម អាចនឹងមានការពុលអ៊ីដ្រូសែនស៊ុលផួកើតឡើងដោយសារតែការពុកផុយ ការរលួយ និងបាក់តេរីដែលកាត់បន្ថយសារធាតុស៊ុលហ្វាតនៅខាងក្នុងធុង អាង បំពង់ លូទឹក លូទឹកសំអុយ ប្រឡាយ ឬរណ្តៅដែលមាន ឬធ្លាប់មានទឹកស្អុយ ដីរលួយ ទឹកសំណល់ ទឹកខាប់ៗ និងសារធាតុផ្សេងទៀតដែលងាយពុកផុយ និងរលួយ។




អ៊ីដ្រូសែនស៊ុលផួត្រូវបានផលិត

## វិធានការការពារកង្វះអុកស៊ីសែន និងគ្រោះថ្នាក់ផ្សេងៗ៖

① ពិនិត្យកន្លែងដែលមានហានិភ័យខ្វះអុកស៊ីសែន មុនពេលចាប់ផ្តើមការងារ។
② ចាត់តាំងប្រធានប្រតិបត្តិការការងារដែលខ្វះអុកស៊ីសែន។
③ វាស់កំហាប់អុកស៊ីសែន និងកំហាប់អ៊ីដ្រូសែនស៊ុលផួ។
④ អនុវត្តការអប់រំបណ្តុះបណ្តាលពិសេសសម្រាប់បុគ្គលិកដែលធ្វើការងារដោយមិនមានអុកស៊ីសែនគ្រប់គ្រាន់។
* ពេលចាត់តាំងនិយោជិតឱ្យបំពេញភារកិច្ចដែលពាក់ព័ន្ធនឹងការងារដែលធ្វើនៅកន្លែងមានហានិភ័យខ្វះអុកស៊ីសែន ចាំបាច់ត្រូវអនុវត្តការអប់រំបណ្តុះបណ្តាលពិសេសដែលបង្រៀនពីមូលហេតុនៃកង្វះអុកស៊ីសែន រោគសញ្ញា របៀបប្រើឧបករណ៍ខ្យល់ដកដង្ហើម និងវិធីជម្លៀសនិងផ្តល់ការសង្គ្រោះបន្ទាន់ដល់បុគ្គលដែលរងផលប៉ះពាល់ក្នុងករណីមានឧបទ្ទវហេតុ។
⑤ ខ្យល់ចេញចូល
⑥ ប្រើឧបករណ៍ការពារ
⑦ វិធានការសង្គ្រោះបន្ទាន់
⑧ ការពារគ្រោះថ្នាក់បន្ទាប់បន្សំ (ប្រើឧបករណ៍ខ្យល់ដកដង្ហើមពេលជួយសង្គ្រោះមនុស្ស)។
⑨ វិធានការផ្សេងទៀត

# 12 សារៈសំខាន់នៃទំនាក់ទំនងជាមួយសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស

① ការលើកកម្ពស់ការប្រាស្រ័យទាក់ទង

- ការប្រាស្រ័យទាក់ទងជាមួយសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស នឹងជួយឱ្យយល់អំពីសមត្ថភាពប្រើប្រាស់ភាសាជប៉ុនរបស់ពួកគេ និងភាពខុសគ្នានៃរបៀបរស់នៅ ដែលនឹងលើកកម្ពស់វិធានការសុខភាពនិងសុវត្ថិភាពក្រោមផែនការការងារសមស្រប។

② លើកកម្ពស់កម្រិតយល់ដឹងរបស់សិក្ខាកាមអំពីបច្ចេកវិទ្យាសុខភាពនិងសុវត្ថិភាព ស្លាកសញ្ញាសុវត្ថិភាព ។ល។

- សម្រាប់វាក្យសព្ទសុខភាពនិងសុវត្ថិភាព និងសញ្ញាសុវត្ថិភាពដែលទាក់ទងនឹងការងារ សូមប្រើការពិពណ៌នាជាភាសាកំណើតរបស់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស និងរូបភាពពន្យល់ ដើម្បីឱ្យសិក្ខាកាមអាចយល់បានដោយលម្អិត។

③ សារៈសំខាន់នៃការអប់រំសុខភាពនិងសុវត្ថិភាពភ្លាមៗបន្ទាប់ពីមកដល់ប្រទេសជប៉ុន

- ដោយសារតែលទ្ធភាពកើតមានការរងរបួសឧស្សាហកម្មកើតឡើងនៅពេលជួលសិក្ខាកាម ដូច្នេះសំខាន់បំផុតត្រូវផ្តល់ការអប់រំសុខភាពនិងសុវត្ថិភាពនៅពេលជួលសិក្ខាកាម ដើម្បីបង្ការការរងរបួសឧស្សាហកម្មនៅដំណាក់កាលដែលសិក្ខាកាមទទួលបានជំនាញសម្រាប់ការងារដែលពួកគេមិនស្គាល់។
- ដោយសារសិក្ខាកាមខ្វះបទពិសោធន៍ធ្វើការនៅប្រទេសជប៉ុននៅពេលផ្តល់ការណែនាំការងារ សូមពន្យល់ដោយយកចិត្តទុកដាក់ ខណៈពេលបង្ហាញពីរបៀបធ្វើការងារ ដើម្បីឱ្យសិក្ខាកាមយល់អំពីការណែនាំទាំងនោះ។

④ អនុវត្តសកម្មភាពសុខភាពនិងសុវត្ថិភាពប្រចាំថ្ងៃ។

- អនុវត្តសកម្មភាពសុខភាព និងសុវត្ថិភាពប្រចាំថ្ងៃ។ (5S , TBM និង KYK) សូម្បីតែនៅពេលសិក្ខាកាមស៊ាំនឹងការងារក្រោយពីទទួលបានកម្រិតបទពិសោធន៍ការងារនៅក្នុងប្រទេសជប៉ុនហើយក៏ដោយ។

⑤ ពេលតម្រូវឱ្យមានវិធានការសង្គ្រោះបន្ទាន់

- អប់រំសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសជាទៀងទាត់ ដើម្បីឱ្យពួកគេអាចបង្កើនសមត្ថភាពប្រើប្រាស់ភាសាជប៉ុនរបស់ពួកគេ និងយល់បានគ្រប់គ្រាន់អំពីភាសាជប៉ុនដែលបង្ហាញសម្រាប់បញ្ហាគ្រោះថ្នាក់ និងបញ្ហាដែលបានហាមឃាត់។ ដូចគ្នានេះដែរ ត្រូវរៀបចំក្តារខៀនជូនដំណឹងដែលមានព័ត៌មានទំនាក់ទំនង និងព័ត៌មានផ្សេងទៀត ដើម្បីជូនដំណឹង និងពន្យល់ជាមុនអំពីរបៀបទាក់ទងអ្នកដទៃ ឬសេវាសង្គ្រោះបន្ទាន់អំឡុងពេលមានស្ថានភាពអាសន្នកើតឡើង។
- ផ្តល់ការណែនាំប្រចាំថ្ងៃដល់សិក្ខាកាម ដើម្បីធានាថា ពួកគេស្រែកប្រាប់មនុស្សជុំវិញខ្លួន និងធ្វើសកម្មភាពដោយភាពស្ងប់ស្ងាត់តាមវេជ្ជបញ្ជា នៅពេលមានឧបទ្ទវហេតុកើតឡើង។

⑥ គំនិតផ្តួចផ្តើមសម្រាប់វិញ្ញាបនបត្រ GAP

- ត្រូវពន្យល់ដល់សិក្ខាកាមថា ក្នុងវិស័យកសិកម្មជប៉ុន យើងខិតខំប្រឹងប្រែងដើម្បីទទួលបានវិញ្ញាបនបត្រ GAP (Good Agricultural Practice) ដើម្បីរក្សាសុវត្ថិភាពចំណីអាហារប្រកបដោយនិរន្តរភាព ថែរក្សាបរិស្ថាន និងរក្សាសុខភាពនិងសុវត្ថិភាពការងារ។

# 13 ការអនុវត្តការពិនិត្យសុខភាព

ស្ថាប័នអនុវត្តទាំងអស់ ត្រូវតែអនុវត្តការពិនិត្យសុខភាពសម្រាប់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសដោយផ្អែកលើច្បាប់សុខភាព និងសុវត្ថិភាពឧស្សាហកម្ម។

## ការពិនិត្យសុខភាពទូទៅ

នៅពេលជួលសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសថ្មី ពួកគេត្រូវតែទទួលការពិនិត្យសុខភាពសម្រាប់ផ្នែកខាងក្រោមតាមច្បាប់តម្រូវ។ (មាត្រា 43 នៃបទបញ្ញត្តិសុខភាពនិងសុវត្ថិភាព)

ផ្នែកដែលត្រូវពិនិត្យសុខភាពនៅពេលជួលសិក្ខាកាមត្រូវបានបង្ហាញខាងក្រោមចាប់ពី ① រហូតដល់ ⑪។

① ប្រវត្តិសុខភាពនិងការងារ
② រោគសញ្ញាអត្តនោម័ត និងសត្យានុម័ត
③ កម្ពស់ ទម្ងន់ រង្វង់ចង្កេះ ភ្នែក និងការស្តាប់
④ ការពិនិត្យកាំរស្មីអ៊ិចដើមទ្រូង
⑤ សម្ពាធឈាម
⑥ ការពិនិត្យភាពស្លេកស្លាំង (ការពិនិត្យបរិមាណអេម៉ូក្លូប៊ីននិងចំនួនអេរីត្រូស៊ីត)
⑦ ការពិនិត្យមុខងារថ្លើម (ការពិនិត្យ GOT, GPT, -GTP)
⑧ ការពិនិត្យកម្រិតសារធាតុខ្លាញ់ក្នុងឈាម
⑨ ការពិនិត្យកម្រិតជាតិស្ករក្នុងឈាម
⑩ ការវិភាគទឹកនោម (ពិនិត្យជាតិស្ករ និងប្រូតេអ៊ីនក្នុងទឹកនោម)
⑪ ការពិនិត្យគំនូសចលនាបេះដូងដោយប្រើចរន្តអគ្គិសនី



ការពិនិត្យសុខភាពនៅពេលជួល រួមចំណែកដល់ការបែងចែកបុគ្គលិកសមស្រប និងជួយគ្រប់គ្រងសុខភាពរបស់ពួកគេ បន្ទាប់ពីពួកគេចូលធ្វើការ។ ជាងនេះទៀត ចាំបាច់ត្រូវអនុវត្តការពិនិត្យទាំងនេះនៅពេលជួល រួមទាំងការពិនិត្យកាំរស្មីអ៊ិចដើមទ្រូង ដែលអាចមានលទ្ធភាពរកឃើញករណីជំងឺរបេង ព្រោះមានការកើនឡើងនៃចំនួនជនបរទេសដែលឆ្លងជំងឺរបេងកាលពីឆ្នាំកន្លងទៅថ្មីៗនេះ។

ចំណុចគន្លឹះ

< វិធានការការពារការឆ្លងនៅកន្លែងធ្វើការ (ជំងឺរបេង) -ការឆ្លើយតបនៅពេលមានការផ្ទុះឡើងនៃជំងឺរបេង ->

អនុវត្តការឆ្លើយតបចំពោះជំងឺរបេង ដោយផ្អែកលើច្បាប់ស្តីពីជំងឺឆ្លង អំពីការការពារជំងឺឆ្លង និងការថែទាំសុខភាពសម្រាប់អ្នកជំងឺដែលមានជំងឺឆ្លង។ ពេលមានការផ្ទុះឡើងនៃជំងឺរបេងនៅកន្លែងធ្វើការស្ថង់ដា ដោយមិនរាប់បញ្ចូលស្ថាប័នវេជ្ជសាស្ត្រ ការពិនិត្យអ្នកដែលប្រឈមនឹងជំងឺគឺជាការចាំបាច់ ក្នុងគោលដៅចម្បងដើម្បីរកឱ្យឃើញ និងឆ្លើយតបភ្លាមៗចំពោះអ្នកដែលឆ្លង ឬអ្នកដែលអាចនឹងឆ្លងជំងឺរបេង។

ការឆ្លើយតបជាមូលដ្ឋានគឺត្រូវអនុវត្តតាមការណែនាំដែលទទួលបានពីមណ្ឌលសុខភាពសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ តួនាទីចម្បងរបស់ក្រុមហ៊ុនអាជីវកម្មគឺកំណត់អត្តសញ្ញាណមនុស្សដែលប្រឈមមុខ ផ្តល់ការពន្យល់ដល់បុគ្គលិកនិយោជិត ណែនាំអ្នកដែលមិនបានទទួលការពិនិត្យសុខភាពតាមកាលកំណត់ឱ្យធ្វើដូច្នោះ ហើយធ្វើការពិនិត្យអ្នកដែលបានប៉ះពាល់។

## ការពិនិត្យសុខតាមពលកំណត់

ការពិនិត្យសុខភាពតាមកាលកំណត់ ត្រូវតែធ្វើឡើងមួយឆ្នាំម្តង ដើម្បីពិនិត្យផ្នែករាងកាយតាមច្បាប់តម្រូវ សម្រាប់បុគ្គលិកនិយោជិតធ្វើការពេញម៉ោង (សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស)។ (មាត្រា 44 នៃបទបញ្ញត្តិសុខភាពនិងសុវត្ថិភាព)

ការពិនិត្យសុខភាពផ្នែករាងកាយតាមកាលកំណត់ ត្រូវបានបង្ហាញខាងក្រោមចាប់ពី ① រហូតដល់ ⑪។

① ប្រវត្តិសុខភាពនិងការងារ

② រោគសញ្ញាអត្តនោម័ត និងសត្យានុម័ត

③ កម្ពស់ ទម្ងន់ រង្វង់ចង្កេះ ភ្នែក និងការស្តាប់

④ ការពិនិត្យកាំរស្មីអ៊ិចដើមទ្រូង និងការពិនិត្យកំហាក

⑤ សម្ពាធឈាម

⑥ ការពិនិត្យភាពស្លេកស្លាំង (ការពិនិត្យបរិមាណអេម៉ូក្លូប៊ីននិងចំនួនអេរីត្រូស៊ីត)

⑦ ការពិនិត្យមុខងារថ្លើម (ការពិនិត្យ GOT, GPT, -GTP)

⑧ ការពិនិត្យកម្រិតសារធាតុខ្លាញ់ក្នុងឈាម

⑨ ការពិនិត្យកម្រិតជាតិស្ករក្នុងឈាម

⑩ ការវិភាគទឹកនោម (ពិនិត្យជាតិស្ករ និងប្រូតេអ៊ីនក្នុងទឹកនោម)

⑪ ការពិនិត្យគំនូសចលនាបេះដូងដោយប្រើចរន្តអគ្គិសនី

# 14 ឧទាហរណ៍អំពីការរងរបួសឧស្សាហកម្ម

## ឧទាហរណ៍អំពីការរងរបួសឧស្សាហកម្មដែលពាក់ព័ន្ធនឹងសិក្ខាកាមកម្មសិក្សាការីបច្ចេកទេស ក្នុងការងារទាក់ទងនឹងវិស័យកសិកម្ម

ជាចុងក្រោយ យើងនឹងបង្ហាញឧទាហរណ៍មួយចំនួននៃការរងរបួសឧស្សាហកម្ម។ សូមពិចារណាវិធីសាស្ត្រអនុវត្តការងារប្រកបដោយសុវត្ថិភាព ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ និងប្រើប្រាស់បញ្ជីត្រួតពិនិត្យនៅចុងបញ្ចប់នៃផ្នែកនេះ។

### ឧទាហរណ៍1

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសដែលកំពុងបញ្ជាម៉ាស៊ីនច្រូតកាត់សម្រាប់ការងារប្រមូលផល បានព្យាយាមដកឫសស្មៅជាប់នឹងម៉ាស៊ីនចេញ ដោយយកដៃដាក់ក្នុងផ្នែកវិលរបស់ម៉ាស៊ីន ដែលបណ្តាលឱ្យ ម្រាមដៃរបស់គាត់ត្រូវម៉ាស៊ីនទាញចូល ហើយរងរបួស។



### ដើម្បីការពារឧបទ្ទវហេតុ

ណែនាំសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសជាមុន ឱ្យពន្លត់ម៉ាស៊ីនជានិច្ចនៅពេលដកគ្រឿងរាំងស្ទះ ដូចជាឫសស្មៅជាដើម ចេញពីម៉ាស៊ីន។ បន្ថែមលើនេះ ប្រសិនបើម៉ាស៊ីនមានផ្លែកាត់ ត្រូវពាក់ស្រោមដៃដែលធន់នឹងការមុត ហើយប្រើឧបករណ៍សមស្របដើម្បីដកឫសស្មៅចេញ។

### ឧទាហរណ៍ 2

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសដែលកំពុងតម្រៀបខ្ទឹមបារាំង បានព្យាយាមយកដើមដែលធ្លាក់លើកងវិល ហើយស្រោមដៃរបស់ពួកគាត់បានជាប់នៅប្រឡោះកងនោះ បណ្តាលឱ្យគាត់របួសដៃស្តាំ។



### ដើម្បីការពារឧបទ្ទវហេតុ

ការពាក់ស្រោមដៃអាចបណ្តាលឱ្យមានគ្រោះថ្នាក់ អាស្រ័យលើប្រភេទនៃការងារដែលកំពុងអនុវត្ត។ ដូច្នេះ ស្ថាប័នអនុវត្តគួរតែចែងថាតើត្រូវតែប្រើស្រោមដៃ ឬមិនប្រើសម្រាប់ការងារជាក់លាក់ និងផ្តល់ការណែនាំសមស្របដល់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស។

ជាងនេះទៀត ត្រូវប្រាកដថាត្រូវពន្លត់ម៉ាស៊ីន មុនពេលយកវត្ថុអ្វីមួយចេញ អាស្រ័យលើស្ថានភាពជាក់ស្តែង ដូចជាទំហំរបស់វត្ថុដែលត្រូវដកចេញនោះជាដើម។

## ឧទាហរណ៍3

សិក្ខាកាមកម្មសិក្សាការីផ្នែកបច្ចេកទេសដែលកំពុងដាំកូនស្ពៃដោយប្រើម៉ាស៊ីនដាំ បានព្យាយាមយកថ្មតូចៗដែលជាប់នៅចន្លោះម៉ាស៊ីនដាំនិងកង់របស់វាចេញ ប៉ុន្តែស្រោមដៃរបស់គាត់បានជាប់នៅក្នុងម៉ាស៊ីន បណ្តាលឱ្យគាត់របួសម្រាមដៃស្តាំ។

## ឧទាហរណ៍ 4

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស ដែលកំពុងកិនដើមឈើងាប់ដោយប្រើម៉ាស៊ីនកិនឈើ ព្យាយាមឈូសកម្ទិចកម្ទីដែលនៅខាងមុខម៉ាស៊ីនចិញ្ច្រាំឈើចេញ ប៉ុន្តែត្រូវបានទាញចូលទៅក្នុងផ្លែកាត់វិលរបស់ម៉ាស៊ីន បណ្តាលឱ្យរបួសមេជើងខាងឆ្វេងរបស់គាត់។

## ឧទាហរណ៍5

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសម្នាក់ បានប៉ះកុងតាក់បញ្ឈប់ម៉ាស៊ីនវេចខ្ចប់ស្វ័យប្រវត្តិដោយចៃដន្យពេលកំពុងសម្អាតវា។ ម៉ាស៊ីនវេចខ្ចប់ដោយស្វ័យប្រវត្តិបានចាប់ផ្តើមដំណើរការ ដែលបណ្តាលឱ្យដៃស្តាំរបស់គាត់ត្រូវបានជាប់ និងរងរបួសនៅចន្លោះផ្នែកដែលមានចលនារបស់ម៉ាស៊ីន។

## ឧទាហរណ៍ 6

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសម្នាក់ដែលកំពុងដំឡើងថង់ផ្លាស្ទិកមួយដុំទៅក្នុងម៉ាស៊ីនវេចខ្ចប់ស្វ័យប្រវត្តិ បានជាប់និងរងរបួសដៃស្តាំរបស់គាត់នៅចន្លោះផ្នែកមានចលនានៅលើម៉ាស៊ីន នៅពេលដែលវាចាប់ផ្តើមដំណើរការដោយមិនបានរំពឹងទុក ។

## ឧទាហរណ៍7

សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសម្នាក់ ដែលកំពុងបញ្ជាស៊ីនខ្ចប់ផ្សិត បានព្យាយាមជួសជុលបញ្ហាហ្វីលវេចខ្ចប់ បណ្តាលឱ្យដៃស្តាំរបស់គាត់ត្រូវជាប់ និងរងរបួសដោយសារឧបករណ៍កាត់ និងអ៊ុតនៅលើម៉ាស៊ីន។

## ឧទាហរណ៍8

ខណៈពេលកំពុងលើកឈើដែលចងដោយខ្សែពួរជាប់នឹងចំពួយលើករបស់រថយន្តលើកដាក់ទំនិញ សិក្ខាកាមកម្មសិក្សាការីបច្ចេកទេសបានព្យាយាមដាក់បំពង់ដែកនៅខាងក្រោមកន្លែងលើក ប៉ុន្តែខ្សែពួរបានរបូត ហើយឈើនោះបានធ្លាក់ចេញ បណ្តាលឱ្យរបួសមេដៃឆ្វេងរបស់សិក្ខាកាមរូបនោះ។

## ឧទាហរណ៍ 9

នៅពេលប្រើប៉ែលអ៊ីជ្រូលិកព្យាយាមរើរបងដោយមានសិក្ខាកាមកម្មសិក្សាការីបច្ចេកទេសឈរលើនោះ ជើងរបស់សិក្ខាកាមរូបនោះបានជាប់និងរងរបួសដោយសារដងស៊ីឡាំងរបស់ប៉ែលអ៊ីជ្រូលិក។

## ពិនិត្យ និងគូសធីកចំណុចនីមួយៗ។

| | | |
|---|---|---|
| 1 | តើបានចាត់តាំងអ្នកគ្រប់គ្រងផ្នែកសុខភាពនិងសុវត្ថិភាពដែរឬទេ?<br>(ដូចជា អ្នកតស៊ូមតិផ្នែកសុខភាពនិងសុវត្ថិភាព ឬអ្នកតស៊ូមតិផ្នែកសុវត្ថិភាពជាដើម*) | ☐ |
| 2 | តើម៉ាស៊ីននិងគ្រឿងបរិក្ខារត្រូវគ្នានឹងគម្រប និងឧបករណ៍សុវត្ថិភាពដែរឬទេ? | ☐ |
| 3 | តើមានការពិនិត្យនិងជួសជុលដើម្បីធានាថាអាចប្រើប្រាស់ម៉ាស៊ីននិងគ្រឿងបរិក្ខាដោយសុវត្ថិភាពដែរឬទេ? | ☐ |
| 4 | តើកន្លែងធ្វើការ ស្អាត មានរបៀបរៀបរយដែរឬទេ? | ☐ |
| 5 | តើអ្នកឱ្យសិក្ខាកាមប្រើប្រាស់ឧបករណ៍ការពារ ដើម្បីអាចធ្វើការងារបានដោយសុវត្ថិភាពដែរឬទេ?<br>(ស្បែកជើងកវែងសុវត្ថិភាព ខ្សែក្រវាត់សុវត្ថិភាព មួកសុវត្ថិភាព ម៉ាស់ការពារឧស្ម័ន ។ល។) | ☐ |
| 6 | តើមានផ្តល់ការអប់រំអំពីសុខភាពនិងសុវត្ថិភាពដែរឬទេ?<br>(នៅពេលជួល ឬពេលផ្លាស់ប្តូរប្រភេទការងារ ។ល។) | ☐ |
| 7 | តើអ្នកប្រាកដថាបានធ្វើឱ្យសិក្ខាកាមយល់ដឹងអំពីនីតិវិធីធ្វើការងារដែរឬទេ?<br>ធ្វើដោយរបៀបណា? ☐ជាភាសាជប៉ុន ☐ជាភាសាកំណើតរបស់ពួកគេ ☐អ្នកណែនាំបានបង្ហាញ | ☐ |
| 8 | តើអ្នកឱ្យសិក្ខាកាមរៀនភាសាជប៉ុនដែលចាំបាច់និងសញ្ញាមូលដ្ឋាន ដើម្បីឱ្យពួកគេអាចយល់អំពីការណែនាំ និងព័ត៌មានផ្សេងទៀត ដើម្បីការពារការរងរបួសឧស្សាហកម្មដែរឬទេ? | ☐ |
| 9 | តើអ្នកប្រើរូបភាពពន្យល់ និងវត្ថុផ្សេងទៀត ដើម្បីធ្វើឱ្យសិក្ខាកាមងាយស្រួលយល់ពីសញ្ញា និងរូបបង្ហាញក្នុងការការពារការរបួសឧស្សាហកម្មដែរឬទេ? | ☐ |
| 10 | តើអ្នកចូលរួមជាមួយសិក្ខាកាមដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការងារដែលតម្រូវឱ្យពួកគេទទួលបានអាជ្ញាប័ណ្ណ ឬបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញដែរឬទេ? | ☐ |

* ច្បាប់ស្តីពីសុខភាពនិងសុវត្ថិភាពឧស្សាហកម្ម តម្រូវឱ្យចាត់តាំង "អ្នកតស៊ូមតិផ្នែកសុខភាពនិងសុវត្ថិភាព" នៅកន្លែងធ្វើការដែលប្រើបុគ្គលិកធម្មតាចាប់ពី 10 នាក់ ដល់ក្រោម 50 នាក់ ខណៈដែល "អ្នកគ្រប់គ្រងសុវត្ថិភាព (បុគ្គលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)" ត្រូវបានចាត់តាំងនៅកន្លែងធ្វើការដែលប្រើបុគ្គលិកធម្មតាជាង 50 នាក់នៅក្នុងឧស្សាហកម្មដូចជារុក្ខាប្រមាញ់ ជាដើម។
កសិកម្មត្រូវបានលើកលែងពីតម្រូវការនៃការចាត់តាំងអ្នកជំនាញទាំងនេះ។ ទោះយ៉ាងណាក៏ដោយ យកល្អត្រូវចាត់តាំងបុគ្គលដែលទទួលខុសត្រូវលើការលើកកម្ពស់វិធានការសុវត្ថិភាពជា "អ្នកតស៊ូមតិផ្នែកសុវត្ថិភាព" និងអនុវត្តសកម្មភាពដូចជា 5S ជាដើម ដើម្បីផ្តល់វិធានការសុវត្ថិភាពក្នុង ការបណ្តុះបណ្តាលកម្មសិក្សាការីបច្ចេកទេស។





# ការរៀបចំការិយាល័យសម្រាប់អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស / ការិយាល័យប្រចាំតំបន់ និងអាសយដ្ឋានការិយាល័យសាខា

| ឈ្មោះការិយាល័យ | នីតិវិធីគ្រប់គ្រង | លេខកូដប្រៃសណីយ៍ | អាសយដ្ឋាន | ទូរសព្ទលេខ |
|---|---|---|---|---|
| ការិយាល័យកណ្តាល | – | 108-0022 | LOOP-X 3F, 3-9-15, Kaigan, Minato-ku, Tokyo | 03-6712-1523 (លេខទូរសព្ទការីចម្បង) 03-3453-8000 (មជ្ឈមណ្ឌលទំនាក់ទំនង) |
| ការិយាល័យនៅ Sapporo | Hokkaido | 060-0034 | Maruito Kita4-jo Bldg. 5F, 2-8-2 Kita4-johigashi, Chuo-ku, Sapporo-shi, Hokkaido | 011-596-6445 (ផ្នែកណែនាំ) |
| ការិយាល័យនៅ Sendai | Aomori, Iwate, Miyagi, Akita, Yamagata, Fukushima | 980-0803 | Sendai Fukoku Seimei Bldg. 6F, 1-2-1 Kokubuncho, Aoba-ku, Sendai-shi, Miyagi | 022-398-6126 (ផ្នែកណែនាំ) |
| ការិយាល័យក្រុង Tokyo | Tochigi, Gunma, Saitama, Chiba, Tokyo, Kanagawa, Yamanashi | 101-0041 | Urban Center Kanda Sudacho 4F, 2-7-2 Kandasudacho, Chiyoda-ku, Tokyo | 03-6433-9971 (ផ្នែកណែនាំ) |
| សាខានៅ Mito | Ibaraki | 310-0062 | Asahi Seimei Mito Bldg. 2F, 1-2-40 Omachi, Mito-shi, Ibaraki | 029-350-8856 (ផ្នែកណែនាំ) |
| សាខានៅ Nagano | Niigata, Nagano | 380-0825 | Nakajima Kaikan Bldg. 6F, 1361 Suehirocho, Minaminagano, Nagano-shi, Nagano | 026-217-3556 (លេខទូរសព្ទការីចម្បង) |
| ការិយាល័យនៅ Nagoya | Shizuoka, Gifu, Aichi, Mie | 460-0008 | Nikken/Sumisei Bldg. 5F, 4-15-32 Sakae, Naka-ku, Nagoya-shi, Aichi | 052-684-8412 (ផ្នែកណែនាំ) |
| សាខានៅ Toyama | Toyama, Ishikawa, Fukui | 930-0004 | Toyama Kogin Bldg. 11F, 5-13 Sakurabashidori, Toyama-shi, Toyama | 076-481-7560 (ផ្នែកណែនាំ) |
| ការិយាល័យនៅ Osaka | Shiga, Kyoto, Osaka, Hyogo, Nara, Wakayama | 541-0043 | Osaka Asahi Seimei Bldg. 4F, 4-2-16 Koraibashi, Chuo-ku, Osaka-shi, Osaka | 06-6210-3722 (ផ្នែកណែនាំ) |
| ការិយាល័យនៅ Hiroshima | Tottori, Shimane, Okayama, Hiroshima, Yamaguchi | 730-0051 | Hiroshima Rijodori Bldg. 3F, 3-1-9 Otemachi, Naka-ku, Hiroshima-shi, Hiroshima | 082-207-3126 (ផ្នែកណែនាំ) |
| ការិយាល័យនៅ Takamatsu | Tokushima, Kagawa | 760-0023 | Takamatsu Kotobukicho Prime Bldg. 7F, 2-2-10 Kotobukicho, Takamatsu-shi, Kagawa | 087-802-5850 (លេខទូរសព្ទការីចម្បង) |
| សាខានៅ Matsuyama | Ehime, Kochi | 790-0003 | Gibraltar Seimei Matsuyama Bldg. 2F, 7-1-21 Sanbancho, Matsuyama-shi, Ehime | 089-909-4110 (លេខទូរសព្ទការីចម្បង) |
| ការិយាល័យនៅ Fukuoka | Fukuoka, Saga, Nagasaki, Oita, Okinawa | 812-0029 | Nikkan Kogyo Shinbun Seibu Branch Bldg. 5F, 1-1 Komondomachi, Hakata-ku, Fukuoka-shi, Fukuoka | 092-710-4083 (ផ្នែកណែនាំ) |
| សាខានៅ Kumamoto | Kumamoto, Miyazaki, Kagoshima | 860-0806 | MY Kumamoto Bldg. 8F, 1-7 Hanabatacho, Chuo-ku, Kumamoto-shi, Kumamoto | 096-223-6470 (ផ្នែកណែនាំ) |

សៀវភៅណែនាំវិធានការសុខភាពនិងសុវត្ថិភាពសម្រាប់សិក្ខាកាមកម្មសិក្សាការីបច្ចេកទេស
<ការងារទាក់ទងនឹងវិស័យកសិកម្ម> ឯកសារជាភាសាខ្មែរ

ចេញផ្សាយខែមីនា ឆ្នាំ 2025

រៀបចំនិងចេញផ្សាយដោយ៖ អង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស
LOOP-X 3F, 3-9-15, Kaigan, Minato-ku, Tokyo, 108-0022
គេហទំព័រ https://www.otit.go.jp/

បកប្រែនិងកែសម្រួលដោយ ក្រុមហ៊ុន Torindo Co., Ltd.
6F PMO Tamachi, 5-31-17 Shiba, Minato-ku, Tokyo 108-0014
គេហទំព័រ https://torindo.ne.jp

សៀវភៅណែនាំនេះត្រូវបានរៀបចំដោយផ្អែកតាមច្បាប់ ចាប់ពីខែតុលា ឆ្នាំ 2024 ។